## ប្លង់គោលប្រើប្រាស់ដីក្រុងកំពត

### ចក្ខុវិស័យឆ្នាំ២០៣០





អាសយដ្ឋានៈ ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរសព្ទ/ទូរសារ (៨៥៥) ២៣ ២១៥ ៦៦០ / ២៣ ២១៥ ២៧៧

គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabitnet!gmail.com



ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០


ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# ប្លង់គោលប្រើប្រាស់ដីក្រុងកំពត

## ចក្ខុវិស័យឆ្នាំ២០៣០


រៀបចំដោយ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

បោះពុម្ពផ្សាយលើកទី១

ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២, ខែកញ្ញា ឆ្នាំ២០១៨

# ប្លង់គោលប្រើប្រាស់ដីក្រុងកំពត

## ចក្ខុវិស័យឆ្នាំ២០៣០

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

លេខ : ០០៣ សសរ

ថ្ងៃព្រហស្បតិ៍ ៨រោច ខែអាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៨

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ខេត្តកំពត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

-យោងតាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពត

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសម្រេចនេះ។

**ប្រការ ២.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពត និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកំពត ត្រូវរៀបចំផែនការ សម្រាប់អនុវត្តប្លង់គោលប្រើប្រាស់ដីខាងលើនេះ ឱ្យមានប្រសិទ្ធភាព និងត្រូវរាយការណ៍អំពីវឌ្ឍនភាពជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ ៣.-**

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកំពត ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីក្រុងកំពត ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងកំពត មុនពេលកំណត់អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលប្លង់គោលប្រើប្រាស់ដីក្រុងកំពត ត្រូវអនុវត្តតាមនីតិវិធី ដែលមានចែងនៅក្នុងសេចក្តីសម្រេចលេខ ០៤១ សសរ ចុះថ្ងៃទី ២២ ខែកក្កដា ឆ្នាំ ២០១៤ ស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម អភិបាលនៃគណៈអភិបាលខេត្តកំពត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពត និងអភិបាលនៃគណៈអភិបាលក្រុងកំពត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកំពត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ០០៣ សសរ..... ចុះថ្ងៃព្រហស្បតិ៍ ៨រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ត្រូវនឹងថ្ងៃទី០៥..... ខែ.កក្កដា... ឆ្នាំ២០១៨

ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ខេត្តកំពត

# ប្លង់គោលប្រើប្រាស់ដីក្រុងកំពត

## ចក្ខុវិស័យឆ្នាំ២០៣០

**មាតិកា** **ទំព័រ**


**១-សេចក្តីផ្តើម** ........ ១

**២-ចក្ខុវិស័យ** ........ ២

**២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម** ........ ២

**២.២-ចក្ខុវិស័យ** ........ ៣

**៣-គោលបំណង និងគោលដៅ** ........ ៣

**៣.១-គោលបំណង** ........ ៣

**៣.២-គោលដៅ** ........ ៣

**៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សក្រុងកំពត** ........ ៤

**៤.១-យុទ្ធស្រាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព** ........ ៤

៤.១.១-ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម ........ ៤

៤.១.២-យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី ........ ៦

**៤.២-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍** ........ ១២

៤.២.១-តំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌ វប្បធម៌ប្រវត្តិសាស្ត្រផ្នែកកណ្តាលក្រុង ........ ១៣

៤.២.២-តំបន់ទេសចរណ៍ធម្មជាតិ ........ ១៤

៤.២.៣-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍ ........ ១៤

៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស ........ ១៤

**៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម** ........ ១៥

៤.៣.១-អ័ក្សអភិវឌ្ឍន៍ភស្តុភារកម្មទេសចរណ៍-ពាណិជ្ជកម្ម តាមផ្លូវជាតិ ........ ១៥

៤.៣.២-អ័ក្សអភិវឌ្ឍន៍ភស្តុភារកម្ម-ឧស្សាហកម្ម តាមផ្លូវអេយស្ម័យយាន ........ ១៥

៤.៣.៣-អ័ក្សអភិវឌ្ឍន៍គាំទ្រពាណិជ្ជកម្មតាមព្រំដែន ........ ១៥

៤.៣.៤-ផ្លូវថ្នល់ ........ ១៥

៤.៣.៥-ផ្លូវទឹក ........ ១៦

៤.៣.៦-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ........ ១៦

៤.៣.៧-ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌ ........ ១៧

៤.៣.៨-ការផ្គត់ផ្គង់ទឹកស្អាត ........ ១៧

**៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក** ........ ១៨

**៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច** ........ ១៩

**៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ** ........ ១៩

៤.៦.១-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង ........ ១៩

៤.៦.២-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ ........ ២០

៤.៦.៣-ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ........ ២១

៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ ........ ២១

**៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ** ........ ២២

**៤.៨-យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន** ........ ២៣

**៥-ផែនការសកម្មភាព** ........ ២៣

**៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម** ........ ២៣

**៥.២-ការផ្សព្វផ្សាយ** ........ ២៤

**៥.៣-ការអនុវត្តគម្រោងតាមវិស័យ** ........ ២៤

៥.៣.១-ការអភិវឌ្ឍក្រុង ........ ២៤

៥.៣.២-ការអភិវឌ្ឍវិស័យទេសចរណ៍ ........ ២៥

៥.៣.៣-ការដឹកជញ្ជូន ........ ២៥

៥.៣.៤-ការពង្រឹងវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផល ........ ២៦

៥.៣.៥-ការគ្រប់គ្រងបរិស្ថាន ........ ២៦

៥.៣.៦-ការគ្រប់គ្រងសំណល់រឹង ........ ២៦

៥.៣.៧-ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ ........ ២៧

៥.៣.៨-ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត ........ ២៧

៥.៣.៩-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍ ........ ២៨

៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ........ ២៨

៥.៤.១-ការអនុវត្តរយៈពេលខ្លី ........ ២៨

៥.៤.២-ការអនុវត្តរយៈពេលមធ្យម ........ ២៨

៥.៤.៣-ការអនុវត្តរយៈពេលវែង ........ ២៨

**៥.៥-គម្រោងអាទិភាព** ........ ២៩

**៦-ធនធានហិរញ្ញវត្ថុ** ........ ៣០

**៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ** ........ ៣១

**៧.១-យន្តការ** ........ ៣១

**៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត** ........ ៣១

**៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍** ........ ៣១

**៨-សេចក្តីសន្និដ្ឋាន** ........ ៣៣

**៩- អនុសាសន៍** ........ ៣៤

**សន្ទានុក្រម** ........ ៣៥

**ឯកសារឧបសម្ព័ន្ធ** ........ ៤០

## ១-សេចក្តីផ្តើម

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញនិងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈប្រកបដោយគុណភាព ប្រសិទ្ធភាព និងសក្តិសិទ្ធភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ខេត្តកំពតស្ថិតនៅទិសនិរតី ក្នុងតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ដែលមានរមណីយដ្ឋានថានសួគ៌បូកគោ និងជាសមាជិកក្លឹបឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក ជាគោលដៅទេសចរណ៍វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ ល្អឯក ពេញនិយមបំផុតនៅព្រះរាជាណាចក្រកម្ពុជា។ ខេត្តមានព្រំប្រទល់ជាប់នឹងខេត្តកែប ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តកំពង់ស្ពឺ និងខេត្តគៀងយ៉ាងប្រទេសវៀតណាម។ មានផ្ទៃដីសរុប៤ ៨៧៣,២គម² បែងចែកជា១ ក្រុង៧ ស្រុក និងឃុំសង្កាត់សរុប៩៣ មានប្រជាជនសរុបចំនួន៦៥២ ៧២៥ នាក់ មានសក្តានុពលធនធានធម្មជាតិ ជាច្រើនដូចជា ឧទ្យានជាតិព្រះមុនីវង្សបូកគោ សត្វសមុទ្រ ស្មៅសមុទ្រ ផ្កាថ្ម ព្រៃកោងកាង ឆ្នេរខ្សាច់ ស្រែអំបិល រ៉ែថ្មកំបោរ ដីកសិកម្ម និងមានសក្តានុពលទេសចរណ៍ធម្មជាតិប្រវត្តិសាស្ត្រ ជាច្រើនមានដូចជា ÷ សំណង់បេតិកភណ្ឌក្រុងកំពត រមណីយដ្ឋានធម្មជាតិថានសួគ៌បូកគោ ល្អាងភ្នំកំពង់ត្រាច ព្រែកត្នោត ភ្នំសិដាអោន ទឹកឈូ ប្រាសាទភ្នំឈ្ងោក សួនសត្វទឹកឈូ ទឹកធ្លាក់បីថ្នាក់ ទំនប់ប្រទាក់ក្រឡា ទំនប់ម្លិច និងរមណីយដ្ឋានភ្នំដូង សហគមន៍ទេសចរណ៍ព្រែកត្នោត ត្រពាំងសង្កែ កែបថ្មី សហគមន៍ទេសចរណ៍លក និងតំបន់កម្សាន្តឆ្នេរសមុទ្រព្រែកអំពិល។ សក្តានុពលទេសចរណ៍ទាំងអស់នេះបានធ្វើឱ្យខេត្តកំពតមានការអភិវឌ្ឍរីកចម្រើនយ៉ាងឆាប់រហ័សស្ទើរគ្រប់វិស័យដូចជា វិស័យសំណង់ កសិកម្ម ឧស្សាហកម្ម សិប្បកម្ម រ៉ែ ថាមពល សេដ្ឋកិច្ច ទេសចរណ៍ សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។

ក្រុងកំពតជាតំបន់ស្នូលនគរូបនីយកម្ម ជាមជ្ឈមណ្ឌលរដ្ឋបាល សេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍នៃ ខេត្តកំពត ដែលជាមជ្ឈមណ្ឌលទីផ្សារជាតិ និង អន្តរជាតិសម្រាប់ផលិតផលកសិកម្ម ពាណិជ្ជកម្ម និងសេដ្ឋកិច្ច។

ក្នុងគោលដៅធានាការគ្រប់គ្រងនិងអភិវឌ្ឍន៍ក្រុងកំពត ប្រកបដោយចីរភាព គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុងកំពត ក្រោមការគាំទ្របច្ចេកទេសដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំនូវ "**ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០**" ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រង និងតម្រង់ទិសអភិវឌ្ឍន៍ដែនដីក្រុងកំពតទាំងមូល ស្របតាមចក្ខុវិស័យគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ប្លង់គោលប្រើប្រាស់ដីនេះត្រូវបានកសាងឡើងដោយការសិក្សាច្បាស់លាស់លើកត្តាភូមិសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន ទេសចរណ៍ និងវប្បធម៌ ព្រមទាំងគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដី និងនគរូបនីយកម្មនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដូចជា ច្បាប់ភូមិបាល ច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្ដីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្ដីពីទេសចរណ៍ ច្បាប់ស្ដីពីព្រៃឈើ ច្បាប់ស្ដីពីជលផល ច្បាប់ស្ដីពីផ្លូវថ្នល់ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្ដីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន សារាចរណែនាំលេខ ០១ស.រ.ណ.ន. ស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាជាដើម។

ចក្ខុវិស័យនៃប្លង់គោលប្រើប្រាស់ដីនេះ មានលក្ខណៈទូលំទូលាយគ្របដណ្ដប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេស សម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការអភិវឌ្ឍគ្រប់កម្រិតក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ធនធានក្រោមដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ជាពិសេសការអភិរក្សស្ថាបត្យកម្មបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្ររបស់ក្រុងកំពត។

# ២-ចក្ខុវិស័យ

## ២.១-ក្របខណ្ឌសេដ្ឋកិច្ច សង្គម

ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ត្រូវបានរៀបចំឡើងដោយបានប្រមូល សិក្សា និងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សម្រេចស្របតាមគោលនយោបាយជាតិស្ដីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយដីធ្លី (សៀវភៅ ស ដីធ្លី) និងអនុក្រឹត្យស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងសេចក្ដីសម្រេចស្ដីពីនីតិវិធីនៃការរៀបចំប្លង់គោលប្រើប្រាស់ដីនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។

ដើម្បីកំណត់ចក្ខុវិស័យដល់ឆ្នាំ២០៣០ ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ត្រូវបានសិក្សាក្របខណ្ឌសេដ្ឋកិច្ច-សង្គមដោយផ្អែកលើសក្តានុពលសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រ តំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា ក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គោលនយោបាយដីធ្លី (សៀវភៅ ស ដីធ្លី) គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀតរបស់ រាជរដ្ឋាភិបាល និងរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ក្រុងកំពតមានផ្ទៃដី៥៤ គីឡូម៉ែត្រក្រឡា ចំនួនប្រជាជននៅឆ្នាំ២០០៨ មានចំនួន៣៦ ៣៦៧ នាក់ ឆ្នាំ២០១៨ មានចំនួន ៣៩ ០៨១ នាក់ និងនៅឆ្នាំ២០៣០ នឹងកើនឡើងដល់៤៩ ១៨៤ នាក់ ផ្អែកតាមការគណនាអត្រាកំណើនប្រចាំឆ្នាំ។ ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ក្រុងកំពត ខេត្តកំពត នៅឆ្នាំ២០០៨ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមាន៤ ៩០៧ នាក់ (២៩,៩៥%) វិស័យឧស្សាហកម្មមាន២ ៣៣៦ នាក់ (១៤,២៦%) និងវិស័យសេវាកម្មមាន៩ ១៤១ (៥៥,៧៩%) ហើយរំពឹងថានៅឆ្នាំ ២០៣០ ចំនួនប្រជាជនធ្វើការក្នុងវិស័យកសិកម្មមានការថយចុះមក៣ ៦៨៩ នាក់ (១៥%) វិស័យឧស្សាហកម្មមានការកើនឡើងដល់៨ ៦០៧ នាក់ (៣៥%) ក្នុងវិស័យសេវាកម្មមានការកើនឡើងដល់១៤ ៧៥៥ នាក់ (៦០%)។

### ២.២-ចក្ខុវិស័យ

ចក្ខុវិស័យដល់ឆ្នាំ២០៣០ នៃប្លង់គោលប្រើប្រាស់ដីក្រុងកំពត គឺសំដៅរៀបចំ និងអភិវឌ្ឍ “ក្រុងកំពតជាក្រុងគុជបៃតង ឆ្នេរសមុទ្រ ធម្មជាតិ វប្បធម៌ និងពាណិជ្ជកម្ម តាមរយៈការអភិវឌ្ឍជាទីក្រុង ១).រមណីយដ្ឋានគុជទេសចរណ៍ឆ្នេរសមុទ្រ ធម្មជាតិ និងវប្បធម៌ ដែលស្អាតបំផុតលើសកលលោក ២).មជ្ឈមណ្ឌលកែច្នៃផលិតផលកសិកម្ម ឧស្សាហកម្ម ៣).ទីផ្សារអន្តរជាតិសម្រាប់ផលិតផលកសិកម្ម និងចែកចាយទំនិញ ៤).ជាទីក្រុងទំនើបដែលមានហេដ្ឋារចនាសម្ព័ន្ធ សេវាកម្មទីក្រុង និងគុណភាពបរិស្ថានរស់នៅល្អប្រសើរ ៥).គ្រប់គ្រង និងអភិបាលកិច្ចល្អ”។

## ៣-គោលបំណង និងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងកំពត មានគោលបំណង និងគោលដៅ ដូចខាងក្រោម÷

### ៣.១-គោលបំណង

ប្លង់គោលប្រើប្រាស់ដីក្រុងកំពតមានគោលបំណង “ធានាការគ្រប់គ្រង និងអភិបាលកិច្ចក្រុងកំពតឱ្យមានប្រសិទ្ធភាពខ្ពស់តាមរយៈការធ្វើសមាហរណកម្ម ការអភិវឌ្ឍ និងការអភិរក្សប្រកបដោយគុណភាព តុល្យភាព សមធម៌ និងចីរភាព”។

### ៣.២-គោលដៅ

ប្លង់គោលប្រើប្រាស់ដីក្រុងកំពត មានគោលដៅ÷

- គ្រប់គ្រងការប្រើប្រាស់ដី និងនគរូបនីយកម្ម ប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្ម
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ចទាក់ទាញ គាំទ្រដល់ការវិនិយោគសាធារណៈនិងវិស័យឯកជន ដើម្បីសមធម៌សង្គម និងផ្តល់ការងារ
- ការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយ ប្រកបដោយប្រសិទ្ធភាព
- លើកកម្ពស់គុណភាព ប្រសិទ្ធភាព នៃការគ្រប់គ្រង ការកែលម្អ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ
- ធ្វើសមាហរណកម្មផែនការរូបវន្ត សេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន និងផែនការតាមវិស័យ ដើម្បីធានាភាពសុខដុមនីយកម្មសង្គម និងការអភិវឌ្ឍប្រកបដោយចីរភាព
- ដោះស្រាយ និងឆ្លើយតបបានល្អតាមតម្រូវការរបស់ប្រជាពលរដ្ឋទូទៅ និងតម្រូវការគ្រប់គ្រងជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច។

## ៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍ និងអភិរក្សក្រុងកំពត

ដើម្បីសម្រេចបានចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ប្លង់គោលប្រើប្រាស់ដីក្រុងកំពតត្រូវបានកំណត់យុទ្ធសាស្ត្រគ្រប់គ្រង អភិបាលកិច្ចនិងការធ្វើសមាហរណកម្ម ការអភិវឌ្ឍនិងការអភិរក្សប្រកបដោយប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមធម៌ ដូចខាងក្រោម÷

### ៤.១-យុទ្ធសាស្ត្រគ្រប់គ្រង ប្រើប្រាស់ដី និងនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព និងចីរភាព

#### ៤.១.១ -ការអភិវឌ្ឍក្រុង និងនគរូបនីយកម្ម

**ក)- តំបន់ក្រុងបច្ចុប្បន្ន**

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលក្រុង សង្កាត់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ជំរុញដាក់លេខផ្ទះ និងឈ្មោះឬលេខផ្លូវ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង
- គ្រប់គ្រងការអភិវឌ្ឍ និងអភិរក្សសំណង់អគារបេតិកភណ្ឌក្នុងតំបន់កណ្តាលក្រុង ផ្សាររាត្រី ផ្សារក្រណាត់ ដែលជាទីកន្លែងកម្សាន្តដ៏មានប្រជាប្រិយភាពរបស់ក្រុង ប្រកបដោយប្រសិទ្ធភាព ចីរភាព សុវត្ថិភាព សោភ័ណភាព សណ្តាប់ធ្នាប់ និងបរិស្ថានរស់នៅល្អ
- គ្រប់គ្រងកែលម្អ និងស្តារឆ្នេរសមុទ្រកម្សាន្ត និងស្តារព្រែកកំពត សួនច្បារតាមមាត់ព្រែក ផ្លូវ និងភ្លើងបំភ្លឺ ឱ្យមានសោភ័ណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើកទាំងពេលយប់ និងពេល

ថ្ងៃ សមស្របជាទីក្រុងគុជបៃតង ដែលជាតារារះនាទិសនិរតី និងជាសមាជិកក្លឹបឆ្នេរដែលស្អាតបំផុតលើសកលលោក

- កែលម្អ និងស្តារផ្លូវជាតិលេខ ៣ និងផ្លូវក្រវាត់ក្រុង ចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ភ្លើងបំភ្លឺ ផ្លាកនិងគំនូសសញ្ញាចរាចរណ៍ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម ឱ្យមានសោភ័ណភាព សណ្តាប់ធ្នាប់ និងគុណភាពបរិស្ថានល្អ
- កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លម្ហសាធារណៈ កំណត់ប្រភេទ ដើមឈើនិងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតងនៅក្នុងក្រុងកំពតស្របទៅតាមតំបន់ប្រើប្រាស់ដីឱ្យមាន សោភ័ណភាពរស់រវើក សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយផាសុខភាព សម្រាប់មនុស្សទាំងអស់គ្នា
- កែលម្អ និងស្តារបណ្តាញហេដ្ឋារចនាសម្ព័ន្ធ មានផ្លូវ បណ្តាញទឹកស្អាត បណ្តាញអគ្គិសនី ការប្រមូលសំណល់រឹងនិងរាវ ឱ្យមានលក្ខណៈសមស្រប និងមានគុណភាព ដើម្បីលើកកម្ពស់គុណភាពរស់នៅ និងសោភ័ណភាពក្រុង
- រៀបចំ និងកំណត់រចនាបថអគារ ពណ៌អគារ និងកំណត់ផ្លាកសញ្ញាផ្សាយពាណិជ្ជកម្ម តាមដងផ្លូវ និងតាមតំបន់ឱ្យមានសណ្តាប់ធ្នាប់និងសោភ័ណភាពល្អ ស្របតាមទីតាំងភូមិសាស្ត្រ ជាទីក្រុងបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ
- កំណត់តំបន់អភិវឌ្ឍន៍ក្រុងឡើងវិញ ដើម្បីលើកកម្ពស់ គុណភាព និងសោភ័ណភាព
- រៀបចំផែនការប្រើប្រាស់ដីដោយកំណត់បទប្បញ្ញត្តិនៃការប្រើប្រាស់ដី ការអភិវឌ្ឍដី ការសាងសង់ ប្លង់លម្អិតនគរូបនីយកម្ម តាមតំបន់នីមួយៗ ស្របតាមទីតាំងភូមិសាស្ត្រ ជាទីក្រុងបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ។

**ខ)- ទិសដៅនគរូបនីយកម្ម**

- ការអភិវឌ្ឍទីក្រុង និងនគរូបនីយកម្មមាននិន្នាការ និងមានលទ្ធភាពពង្រីកឆ្ពោះទៅទិសខាងកើត ក្នុងឃុំត្រពាំងធំ ឆ្ពោះទៅទិសខាងត្បូង ក្នុងឃុំជុំគ្រៀល ឆ្ពោះទៅទិសខាងលិច ក្នុងឃុំបឹងទូក និងឆ្ពោះទៅទិសខាងជើង ក្នុងឃុំកំពង់ក្រែង ស្រុកទឹកឈូ ដោយការពារតំបន់បេតិកភណ្ឌ កសិកម្ម បរិស្ថាន និងតំបន់ធនធានធម្មជាតិ ដោយត្រូវធានាបានកម្រិតដង់ស៊ីតេសមស្រប
- គ្រប់គ្រងការអភិវឌ្ឍ និងធ្វើសមាហរណកម្មការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាពស្របតាមបទដ្ឋានបច្ចេកទេសនគរូបនីយកម្ម និងការអភិវឌ្ឍប្រវន្ត ជាពិសេសបណ្តាញផ្លូវ ប្រព័ន្ធលូ ស្ថានីយប្រព្រឹត្តិកម្មទឹកកខ្វក់ អាងប្រព្រឹត្តិកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ ដោយជំរុញការអភិវឌ្ឍ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ បរិក្ខា និងសេវាកម្មទីក្រុងជាមុន

- ពង្រឹងសមត្ថភាពមន្ត្រីធ្វើផែនការអភិវឌ្ឍ និងគ្រប់គ្រងការអភិវឌ្ឍ ជាពិសេស ប្រសិទ្ធភាពនៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តនិងក្រុង ដែលមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលជាសេនាធិការក្នុងការគ្រប់គ្រង និងអនុវត្តន៍ការងាររៀបចំដែនដី និងនគរូបនីយកម្ម។

## ៤.១.២- យុទ្ធសាស្ត្រគ្រប់គ្រង និងប្រើប្រាស់ដី

តំបន់សិក្សាប្លង់គោលប្រើប្រាស់ដីក្រុងកំពតមានផ្ទៃដីទំហំប្រមាណ៦ ០២៧ ហិកតា ត្រូវបានកំណត់ការប្រើប្រាស់ដីជាពីរប្រភេទគឺ ប្រភេទដីកម្រិតការសាងសង់ និងប្រភេទដីអាចសាងសង់បាន។ ប្រភេទដីកម្រិតការសាងសង់មានផ្ទៃដីទំហំ៣ ៧៣៩ ហិកតា ស្មើនឹង៦២% ក្នុងឆ្នាំ២០១៨ និងមានផ្ទៃដីទំហំ៣ ២៩៤ហិកតា ស្មើនឹង៥៤,៦% នៅឆ្នាំ២០៣០។ ប្រភេទដីអាចសាងសង់បានមានផ្ទៃដីទំហំ២ ២៨៨ ហិកតា ស្មើនឹង៣៨%ក្នុងឆ្នាំ ២០១៨ និងមានផ្ទៃដីទំហំ២ ៧៣៣ ហិកតា ស្មើនឹង៤៥,៤% នៅឆ្នាំ២០៣០។

### ក)- ប្រភេទដីកម្រិតការសាងសង់

ផ្អែកតាមច្បាប់ស្តីពីតំបន់ការពារធនធានធម្មជាតិ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១០ អនុក្រឹត្យលេខ ១៣៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០៥ ស្តីពីតំបន់ការពារធម្មជាតិ និងសារាចរណែនាំលេខ០១ ស.រ.ណ.ន. ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា និងបទដ្ឋានគតិយុត្តជាធរមាន ប្រភេទដីកម្រិតការសាងសង់ត្រូវបានកំណត់ជាតំបន់ ដូចខាងក្រោម÷

១. តំបន់កសិកម្ម ÷ មានផ្ទៃដីប្រមាណ១ ៤៥៩ ហិកតា ស្មើនឹង៣៩%ក្នុងឆ្នាំ២០១៨ និងមានផ្ទៃដី ប្រមាណ ១០១៤ ហិកតា ស្មើនឹង៣០,៥% ក្នុងឆ្នាំ២០៣០ កើន៤៤៥ ហិកតាបើធៀបនឹងឆ្នាំ២០១៨។ តំបន់នេះ រួមមាន ដីស្រែ ដីចម្ការ និងដីកសិដ្ឋានចិញ្ចឹមសត្វ ស្ថិតនៅក្នុងសង្កាត់អណ្តូងខ្មែរ ត្រើយកោះ ក្រាំងអំពិល និងកំពង់បាយ ។ តំបន់នេះត្រូវ÷

- រក្សាការពារផ្ទៃដីកសិកម្ម ដែលមានសក្តានុពល សម្រាប់ដំណាំស្រូវ ម្រេច ធុរេន ដូង និងវារីវប្បកម្ម ដោយអនុវត្តឲ្យបានត្រឹមត្រូវតាមប្លង់គោលប្រើប្រាស់ដីក្រុង
- ធ្វើផែនការគ្រប់គ្រងផ្ទៃដីកសិកម្មដោយធ្វើការកំណត់ និងបែងចែកតំបន់សក្តានុពលកសិកម្មឱ្យបានច្បាស់លាស់ដែលរួមមាន តំបន់កសិកម្មភាគខាងលិច និងខាងត្បូងក្រុង ដែលមានប្រព័ន្ធធារាសាស្ត្រស្រាប់
- អនុវត្តផែនការពង្រីកក្រុងតាមបច្ចេកទេសទំនើបដើម្បីកាត់បន្ថយជាអតិបរមាដល់ផ្ទៃដីកសិកម្ម ដែលបានបម្រុងទុក
- អភិវឌ្ឍកសិកម្ម និងបង្កើនផលិតភាពកសិកម្មតាមភូមិនៅក្នុងតំបន់ខាងលិច ក្នុងសង្កាត់អណ្តូងខ្មែរ និងតំបន់ខាងត្បូងក្នុងសង្កាត់ត្រើយកោះ។

២.តំបន់ស្រែអំបិល និងព្រៃកោងកាង÷ មានផ្ទៃដីប្រមាណ១ ១៤៧ ហិកតា ស្មើនឹង៣១% ក្នុងឆ្នាំ២០១៨ និងមានផ្ទៃដីប្រមាណ១០១៧ ហិកតា ស្មើនឹង៣៤,៥% ក្នុងឆ្នាំ២០៣០ រក្សាផ្ទៃដីដដែលបើធៀបនឹងឆ្នាំ ២០១៨។ តំបន់នេះមានទីតាំងស្ថិតនៅភូមិស្រែ និងភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ។ តំបន់នេះសម្បូរដោយជីវចម្រុះធម្មជាតិ ប្រើប្រាស់ជាគោលដៅទេសចរណ៍ធម្មជាតិ ដែលមានព្រៃកោងកាងដ៏ស្រស់ស្អាត និងប្រើប្រាស់សម្រាប់ផលិតអំបិល ដែលត្រូវអភិរក្ស ថែរក្សាការពារ ទប់ស្កាត់ការកាប់បំផ្លាញ ប្តូរប្រភេទដី ដើម្បីធានាចីរភាពបរិស្ថាន និងធានាការផ្គត់ផ្គង់តម្រូវការប្រើប្រាស់អំបិលទូទាំងប្រទេស និងនាំចេញទៅក្រៅប្រទេស។ ម្យ៉ាងទៀត ត្រូវជំរុញសហគមន៍ផលិតអំបិល និងអ្នកផលិត ខិតខំផលិតអំបិលអោយបានបរិមាណខ្ពស់ និងប្រកបដោយគុណភាព។

ខេត្តកំពតមានឆ្នេរសមុទ្រប្រវែង៦៦,៥ គីឡូម៉ែត្រ និងត្រូវការពារផ្ទៃដីផលិតអំបិលទំហំប្រមាណ ៣ ៨៨៨,៣៧ ហិកតា និងចែកចេញជា០៦ មណ្ឌល÷

- មណ្ឌលត្រើយកោះ÷ មានទីតាំងស្ថិតនៅ ភូមិបឹងតាព្រាម និងភូមិស្រែ សង្កាត់ត្រើយកោះ ក្រុងកំពត មានផ្ទៃដីចំនួន១ ២១១,៩២ ហិកតា
- មណ្ឌលផលិតបឹងរូងទី១÷ មានទីតាំដងស្ថិតនៅ ភូមិជុំគៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ មានផ្ទៃដីទំហំ៨៤៦,៧០ ហិកតា
- មណ្ឌលផលិតបឹងរូងទី២÷ មានទីតាំងស្ថិតនៅ ភូមិជុំគ្រៀល ឃុំជុំគ្រៀល ស្រុកទឹកឈូ មានផ្ទៃដីទំហំ៦៧៤,៩១ ហិកតា
- មណ្ឌលសេះស÷ មានទីតាំងស្ថិតនៅ ភូមិកំពង់ត្នោត ឃុំកូនសត្វ និងភូមិត្រពាំង សង្កែ ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ មានផ្ទៃដីទំហំ៤៥២,៩៥ ហិកតា
- មណ្ឌលបឹងទូក÷ មានទីតាំងស្ថិតនៅភូមិកែបថ្មី ឃុំបឹងទូក ស្រុកទឹកឈូមានផ្ទៃដីទំហំ២៩២,៨៧ ហិកតា
- មណ្ឌលកំពង់ត្រាច÷ មានទីតាំងស្ថិតនៅភូមិលក និងភូមិកោះត្រឹះស្វា ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច មានផ្ទៃដីទំហំ៤០៩,០២ ហិកតា។

៣.តំបន់ព្រៃឈើ÷ មានផ្ទៃដីប្រមាណ៦៥១ ហិកតា ស្មើនឹង២០% ក្នុងឆ្នាំ២០១៨ និងផ្ទៃដីនេះនៅរក្សាដដែលរហូតដល់ឆ្នាំ២០៣០។ តំបន់នេះស្ថិតនៅក្នុងសង្កាត់ត្រើយកោះជាប់នឹងឆ្នេរសមុទ្រ និងស្ថិតនៅសង្កាត់អណ្តូងខ្មែរជាប់នឹងជើងភ្នំបូកគោ ជាតំបន់ភ្នំ និងខ្ពង់រាប។ តំបន់នេះមានអំណោយផលដល់វិស័យទេសចរណ៍ និងជារបាំងការពារខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ហើយចាំបាច់ ត្រូវរក្សាការពារ និងទប់ស្កាត់ការកាប់បំផ្លាញ និងទន្ទ្រានយកដី ដើម្បីធានាចីរភាពបរិស្ថាន។

៤.តំបន់ធនធានទឹក÷ មានផ្ទៃទឹកប្រមាណ៤៨២ ហិកតា ស្មើនឹង១៣% ក្នុងឆ្នាំ២០១៨ គ្របដណ្តប់ផ្នែកខ្លះនៃសង្កាត់ទាំង៥ និងផ្ទៃទឹកនេះនៅរក្សាដដែលរហូតដល់ឆ្នាំ២០៣០។ តំបន់នេះរួមមាន ដែនសមុទ្រ ព្រែក

ស្ទឹង អូរ បឹង ប្រឡាយ ត្រពាំង ទំនប់ទឹក និងបណ្តាញផ្លូវទឹកផ្សេងៗទៀត មានប្រភពមកពីព្រែកទឹកឈូ ព្រែកស្ទឹងកែវ និងពីជួរភ្នំកំចាយ ដែលជាសក្តានុពលដ៏សំខាន់ដែលត្រូវស្តារ និងការពារ ថែរក្សា ដើម្បីប្រើប្រាស់សម្រាប់គាំទ្រដល់ការផ្គត់ផ្គង់ទឹកស្អាត និងវិស័យកសិកម្ម ព្រោះផលិតផលកសិកម្មធម្មជាតិនេះជាធាតុសំខាន់ ក្នុងការផ្គត់ផ្គង់ជាអាហារ សម្រាប់ប្រជាពលរដ្ឋ និងភ្ញៀវទេសចរ។

ដោយឡែកស្រុកទាំងប្រាំពីរផ្សេងទៀតនៃខេត្តកំពតមានប្រព័ន្ធធារាសាស្ត្រសរុបចំនួន៥៤ កន្លែង÷

- ស្រុកទឹកឈូ ÷ មានទំនប់វារីអគ្គិសនីភ្នំកំចាយ និងអាងទឹកចំនួន៤ កន្លែង គឺ ទំនប់ទឹកប្រទ័ក្សក្រឡា អាងទឹកកណ្តោល អាងទឹកប្រវឹកពង និងទំនប់ស្ទឹងកែវ ដែលអាចស្រោចស្រពស្រូវប្រាំងបានចំនួន១ ៣៣០ ហិកតា និងស្រូវវស្សាបានចំនួន៥ ០០០ ហិកតា
- ស្រុកអង្គរជ័យ÷ មានទំនប់អាងទឹកចំនួន៦ កន្លែង គឺទំនប់ដើមថ្កូវ ទំនប់សារដំបង ទំនប់
- អាងទឹកសម្ភូហភាព បឹងត្នោតតាចាង ត្រពាំងរុន និងទំនប់វាលត្បាល់ ក្នុងលទ្ធភាពនៃការស្រោចស្រពស្រូវប្រាំងមានចំនួន៧៩៦ ហិកតា និងស្រូវវស្សា មានចំនួន១ ៥៨០ ហិកតា
- ស្រុកដងទង់÷ មានទំនប់អាងទឹកចំនួន៧ កន្លែង គឺ ទំនប់អាងទឹកគគីរដែក ភ្នំត្រយឹង ត្រពាំងនៀលប៉ាក់ស្លា ច្រកកេស ត្រពាំងក្តារ និងអាងទឹកព្រៃក្រាំង ដែលមានលទ្ធភាពស្រោចស្រពស្រូវប្រាំងចំនួន៩២៨ ហិកតា និងស្រូវវស្សាចំនួន៣ ៧៦៤ ហិកតា
- ស្រុកឈូក÷ មានទំនប់អាងទឹកចំនួន៩កន្លែងគឺ ទំនប់អាងទឹកថ្មពួក អូឃ្លៃ បឹងនិមល អរគុណ ត្រពាំងបឹង កុកអញ្ចាន់ កោះស្លា ត្រពាំងសាម និងអាងទឹកវាលវ៉ាន់ ក្នុងនោះលទ្ធភាពនៃការស្រោចស្រពស្រូវប្រាំងចំនួន៥២ ហិកតា និងស្រូវវស្សាចំនួន៣០១ ហិកតា
- ស្រុកជុំគីរី÷ មានប្រព័ន្ធស្រោចស្រពចំនួន១១ កន្លែង គឺ ទំនប់អាងទឹកស្ទឹងភេ មនោណុប ភូមិអូរ ព្រៃផ្តៅ តាកុច ជិពូវ៉ែន៧៧ មុន្នីវ៉ន ទឹកវាល ទឹកម្ទេច និងទំនប់ទឹកសាលាដំណាក់ អាចស្រោចស្រពលើផ្ទៃដីស្រែប្រាំងចំនួន១ ៧៨៦ ហិកតា និងស្រូវវស្សាចំនួន៤៤៣៨ ហិកតា
- ស្រុកកំពង់ត្រាច÷ មានទំនប់អាងទឹកចំនួន៦ កន្លែង គឺទំនប់ការពារទឹកប្រៃកំពង់គ្រញូង អរច្រនៀង លំពូ អង្គកោះ ភ្នំដំរី និងទំនប់ទឹកការពារទឹកប្រៃថ្មបើក ក្នុងនោះលទ្ធភាពនៃការ ស្រោចស្រពស្រូវប្រាំងចំនួន១ ៣៧២ ហិកតា និងស្រូវវស្សាចំនួន៥ ២១៤ ហិកតា
- ស្រុកបន្ទាយមាស÷ មានទំនប់អាងទឹកចំនួន១១ កន្លែង គឺ ទំនប់អាងទឹកជ្រោះចេក ដំណាក់ចំបក់ ភ្នំទទុង ចុងស្រង់ ស្តុកឈូក ប្រឡាយពោធិតាស៊ុយ ព្រៃក្រឡា ត្នោតចុងស្រល់ ព្រៃឈើ និង ប្រឡាយស្បូវអណ្តែត ដែលមានលទ្ធភាពស្រោចស្រពស្រូវប្រាំងចំនួន៦ ៣០៩ ហិកតា និងស្រូវវស្សាចំនួន ១៧ ៩៨០ហិកតា

គម្រោងអភិវឌ្ឍន៍ និងសាងសង់ក្នុងប្រភេទដីកម្រិតការសាងសង់ តម្រូវឱ្យមានលិខិតអនុញ្ញាតអភិវឌ្ឍដីជាមុន ស្របតាម អនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី

ក្រុង និងទីប្រជុំជន និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/នីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី។ មានតែតំបន់កសិកម្មប៉ុណ្ណោះ ដែលអាចអនុញ្ញាតឱ្យសាងសង់លំនៅឋានផ្ទាល់ខ្លួនបានដែលមិនមានលក្ខណៈអាជីវកម្ម និងអាចសាងសង់រោងសិប្បកម្មសម្រាប់គោលដៅកសិកម្មបានដោយមិនបាច់ធ្វើការកែប្រែទៅជាប្រភេទដីអាចសាងសង់បាន លើកលែងតែតំបន់ណាដែលមានបទដ្ឋានគតិយុត្តកំណត់ដោយឡែក។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់កសិកម្ម ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាស្មើនឹង១០% ឆ្លាតគម្លាតអគារខាងមុខយ៉ាងតិ ១០ ម៉ែត្រ និងចំហៀងសងខាងនិងខាងក្រោយយ៉ាងតិចស្មើនឹងពាក់កណ្តាលគម្លាតអគារខាងមុខ កម្ពស់អគារអតិបរមាស្មើនឹង៨ម៉ែត្រ សួនច្បារដែលអាចជ្រាបទឹកនិងផ្ទៃបៃតងយ៉ាងតិច៦៥% នៃផ្ទៃដីដែលនៅសល់ពីការសាងសង់ និងដាំដើមឈើយ៉ាងតិច១ ដើមសម្រាប់ផ្ទៃក្រឡាដីឡូត៍៤៩ម៉ែត្រក្រឡា។

**ខ)- ប្រភេទដីអាចសាងសង់បាន**

ផ្អែកលើផែនទីប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០ ប្រភេទដីអាចសាងសង់បានត្រូវបានកំណត់ជា១០ តំបន់។ បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់នីមួយៗត្រូវមានផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនច្បារជ្រាបទឹក ការដាំដើមឈើ ផ្លូវតម្រង់ ឆ្លាតគម្លាត កម្ពស់ ចំណតរថយន្ត អាងបង្គន់អនាម័យ អាងប្រព្រឹត្តកម្មទឹកកខ្វក់ ពណ៌អគារ សោភ័ណភាព និងមានរចនាបថស្ថាបត្យកម្មខ្មែរ និង/ឬមានធម្មជាតិត្រឹមត្រូវស្របតាមបទប្បញ្ញត្តិជាធរមាន និងបែងចែកជាតំបន់ប្រើប្រាស់ដី ដូចខាងក្រោម៖

១. **តំបន់លំនៅឋាន÷** មានផ្ទៃដីប្រមាណ៨៣១ ហិកតា ស្មើនឹង៣៦%ក្នុងឆ្នាំ២០១៨ និងកើនដល់ ១០២៣ ហិកតា ស្មើនឹង៣៨% ក្នុងឆ្នាំ២០៣០។ តំបន់នេះ ស្ថិតនៅសង្កាត់កំពង់បាយ កំពង់កណ្តាល ក្រាំងអំពិល អណ្តូងខ្មែរ សង្កាត់ត្រើយកោះ និងត្រូវបានបែងចែកជាតំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាប តំបន់លំនៅឋានជាប់គ្នាកម្ពស់ទាប និងតំបន់លំនៅឋានចម្រុះ ដែលត្រូវរក្សាផ្ទៃបៃតងឱ្យបានសមស្រប។ តំបន់នេះត្រូវបានកំណត់បែងចែកជា៖

- តំបន់លំនៅឋានដាច់ពីគ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
- តំបន់លំនៅឋានជាប់គ្នាដែលមានកម្ពស់ទាបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥
- តំបន់លំនៅឋានដែលមានកម្ពស់មធ្យមត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនី ៣,០
- តំបន់លំនៅឋានចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង ៣,០។

២. **តំបន់សំណង់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ÷** មានផ្ទៃដីប្រមាណ៧,៥ ហិកតា ស្មើនឹង០,៣% ក្នុងឆ្នាំ ២០១៨ និងផ្ទៃដីនេះនៅរក្សាដដែលរហូតដល់ឆ្នាំ២០៣០។ តំបន់នេះស្ថិតនៅក្នុងសង្កាត់កំពង់កណ្ដាល និងសង្កាត់កំពង់បាយ ប្រើប្រាស់ជាគោលដៅទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ ដែលមានសំណង់អគារលំនៅឋាន អគាររដ្ឋបាលសាធារណៈ ផ្សារ សាលារៀន វិហារចិន រោងកុន វិហារ ស្ពាន ដែលបន្សល់ទុករហូតមកដល់បច្ចុប្បន្ន។ តំបន់នេះក៏ត្រូវចាត់ជាតំបន់លំនៅឋានជាប់គ្នា និងដាច់ពីគ្នាដែលមានកម្ពស់ទាប និងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ១,៥ និងអនុញ្ញាតបានត្រឹមតែជួសជុល ថែរក្សា តាមទម្រង់ស្ថាបត្យកម្មដើម កម្ពស់ រចនាបថ និងសោភ័ណភាព។

៣. **តំបន់ពាណិជ្ជកម្ម÷** មានផ្ទៃដីប្រមាណ១៨,៥ ហិកតា ស្មើនឹង០,៨% ក្នុងឆ្នាំ២០១៨ និងកើនដល់ ៤៩,៥ ហិកតា ស្មើនឹង១,៨% ក្នុងឆ្នាំ២០៣០។ តំបន់នេះស្ថិតនៅផ្សារសាមគ្គី ផ្សារក្រណាត់ ផ្សារដីហុយ ផ្សាររាត្រី និងតាមបណ្ដោយផ្លូវជាតិលេខ៣ និងមហាវិថីលេខ៧២៩ និងមហាវិថីលេខ៧០៧ ក្នុងសង្កាត់សង្កាត់កំពង់បាយ ក្រាំងអំពិល និងសង្កាត់កំពង់កណ្ដាល និងត្រូវបែងចែកជាតំបន់ពាណិជ្ជកម្មជាផ្សារ និងតំបន់ពាណិជ្ជកម្មចម្រុះ ដែលត្រូវជំរុញអភិវឌ្ឍលម្ហសាធារណៈ និងផ្ទៃបៃតងឱ្យបានសមស្រប និងត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីដូចខាងក្រោម ៖

- តំបន់ពាណិជ្ជកម្មជាផ្សារ ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៦,០
- តំបន់ពាណិជ្ជកម្មចម្រុះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០។

៤. **តំបន់ចម្រុះ÷** មានផ្ទៃដីប្រមាណ១៩ ហិកតា ស្មើនឹង១% ក្នុងឆ្នាំ២០១៨ និងកើនដល់២៦ ហិកតា ស្មើនឹង ១% ក្នុងឆ្នាំ២០៣០។ តំបន់នេះស្ថិតនៅក្នុង សង្កាត់អណ្ដូងខ្មែរ ក្រាំងអំពិល កំពង់បាយ កំពង់កណ្ដាល និងសង្កាត់ត្រើយកោះ លាយឡំក្នុងតំបន់លំនៅឋាន តំបន់សំណង់បេតិកភណ្ឌ វប្បធម៌ និងតំបន់ពាណិជ្ជកម្ម មានមុខងារប្រើប្រាស់ច្រើនយ៉ាង ដូចជា សិប្បកម្ម ភោជនីយដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ និងសេវាកម្មផ្សេងៗ។ តំបន់នេះត្រូវបានយកចិត្តទុកដាក់ដោយធានាបាននូវបរិស្ថានល្អ និងកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០ ដោយរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

៥. **តំបន់ដឹកជញ្ជូន÷** មានផ្ទៃដីប្រមាណ៤១៣ ហិកតា ស្មើនឹង១៨% ក្នុងឆ្នាំ២០១៨ និងជំរុញអភិវឌ្ឍន៍ឱ្យមានផ្ទៃដីយ៉ាងតិច២៥% ក្នុងឆ្នាំ២០៣០។ តំបន់នេះមានកំពង់ផែទំនិញ ផែទូកនេសាទ ស្ថិតនៅសង្កាត់កំពង់កណ្ដាល ចំណតរថយន្ត ចំណតរ៉ឺម៉ក ស្ថានីយអយស្ម័យយាន ស្ថិតនៅសង្កាត់ក្រាំងអំពិល និងបណ្ដាញផ្លូវទាំងអស់ក្នុងសង្កាត់ទាំងប្រាំ។ តំបន់នេះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,០ ដោយរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

៦. **តំបន់ទេសចរណ៍÷** មានផ្ទៃដីប្រមាណ៨០១ ហិកតា ស្មើនឹង៣១% ក្នុងឆ្នាំ២០១៨ និងកើនដល់៩១២ ហិកតា ស្មើនឹង៣៣% ក្នុងឆ្នាំ២០៣០។ តំបន់ទេសចរណ៍ បែងចែកជា២ គឺតំបន់ទេសចរណ៍ធម្មជាតិ មានផ្ទៃដីប្រមាណ

៣៤០ ហិកតា ស្មើនឹង១២% និងតំបន់ទេសចរណ៍សេវាកម្មទីក្រុងមានផ្ទៃដីប្រមាណ៥៧២ ហិកតាស្មើនឹង ២១%។ តំបន់នេះស្ថិតនៅតាមដងព្រែកកំពត និងតាមបណ្តោយឆ្នេរសមុទ្រ មានទីតាំងក្នុងសង្កាត់កំពង់បាយ កំពង់កណ្តាល អណ្តូងខ្មែរ និងសង្កាត់ត្រើយកោះ។ តំបន់នេះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា ស្មើនឹង១,៥ សម្រាប់តំបន់ទេសចរណ៍ធម្មជាតិតាមដងព្រែក និងកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមា៥,០ សម្រាប់តំបន់ទេសចរណ៍សេវាកម្មទីក្រុង ដោយរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

៧. **តំបន់រដ្ឋបាលនិងសេវាសាធារណៈ÷** មានផ្ទៃដីប្រមាណ៣២ ហិកតា ស្មើនឹង១,៥%ក្នុងឆ្នាំ២០១៨ និងជំរុញអភិវឌ្ឍន៍បន្ថែមស្របតាមតម្រូវការនៃចក្កុវិស័យដល់ឆ្នាំ២០៣០។ តំបន់នេះមួយផ្នែកធំប្រមូលផ្តុំក្នុងសង្កាត់កំពង់កណ្តាល និងមួយផ្នែកទៀតស្ថិតនៅសង្កាត់ទាំង៤។ តំបន់នេះមានជាអាទិ៍ សាលាខេត្ត សាលាក្រុង សាលាសង្កាត់ សាលាដំបូង មន្ទីរ អង្គភាពជុំវិញខេត្ត ទីបញ្ជាការដ្ឋាន ស្នងការដ្ឋាន អធិការដ្ឋាន ប៉ុស្តិ៍នគរបាល សាលារៀន មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព សារមន្ទីរ ប៉ុស្តិ៍ប្រៃសណីយ៍ បណ្ណាល័យ។ តំបន់នេះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០ ដោយរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

៨. **តំបន់លំហសាធារណៈ និងផ្ទៃបៃតង÷** មានផ្ទៃដីប្រមាណ១៦៨ ហិកតា ស្មើនឹង៦%ក្នុងឆ្នាំ២០៣០ ស្ថិតតាមបណ្តោយឆ្នេរសមុទ្រ ព្រែកកំពត សួនច្បារផ្សារក្រណាត់ ទីលានកីឡដ្ឋាន តំបន់លម្ហសាធារណៈក្នុងសង្កាត់ទាំង៥។ តំបន់នេះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង០,១ ដោយរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

៩. **តំបន់វប្បធម៌ និងសាសនា÷** មានផ្ទៃដីប្រមាណ៣៥ ហិកតា ស្មើនឹង១,៥%ក្នុងឆ្នាំ២០១៨ និងផ្ទៃដីនេះនៅរក្សាដដែលរហូតដល់ឆ្នាំ២០៣០។ តំបន់នេះស្ថិតនៅតាមសង្កាត់ទាំង៥ ក្នុងក្រុង រួមមានវត្តអារាមព្រះពុទ្ធសាសនា ព្រះវិហារសាសនា និងទីសក្ការបូជា ទីវាលស្មសាន។ តំបន់នេះត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២,០ ដោយរក្សាផ្ទៃបៃតងឱ្យបានសមស្រប។

១០. **តំបន់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេស÷** មានស្ថានីយផ្គត់ផ្គង់ទឹកស្អាត ស្ថិតក្នុងសង្កាត់អណ្តូងខ្មែរ និងមានស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ដោយធម្មជាតិ ស្ថិតក្នុងសង្កាត់ក្រាំងអំពិល មានផ្ទៃដីទំហំប្រមាណ២,៩១ ហិកតា និងគ្រោងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ នៅឃុំកំពង់សំរោង ស្រុកទឹកឈូ មានផ្ទៃដីទំហំប្រមាណ១០ហិកតា និងគ្រោងទីតាំងស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ នៅភូមិបឹងតាព្រាម សង្កាត់ត្រើយកោះ។ ចំណែកទីលានចាក់សំរាមនៅក្នុងក្រុងពុំមានទេ មានតែមណ្ឌលកែច្នៃដីកំប៉ុស្តិ៍ ចំណែកទីលានចាក់សំរាមបច្ចុប្បន្ន និងទីលានចាក់សំរាមគ្រោងដល់ឆ្នាំ២០៣០ ស្ថិតនៅឃុំព្រៃឃ្មុំ ស្រុកទឹកឈូ មានផ្ទៃដីទំហំប្រមាណ១៧,២ ហិកតា ដែលត្រូវថែរក្សាការពារ និងអភិវឌ្ឍស្របតាមបច្ចេកទេសបរិស្ថាន។

គម្រោងអភិវឌ្ឍ និងសាងសង់ក្នុងប្រភេទដីនេះ តម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន ស្របតាមអនុក្រឹត្យលេខ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ៩៨២ អនក្រ.បក

ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន ប្រកាសលេខ២១៧ ប្រក.ដ.ន.ស. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០១៥ ស្តីពីវិធានគណនាសន្ទស្សន៍ប្រើប្រាស់ដី និងប្រកាសលេខ០៨៧ ដ.ន.ស.ប្រក/ទីក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍដី។

បទប្បញ្ញត្តិនៃការសាងសង់ក្នុងតំបន់ឆ្នេរសមុទ្រក្រុងកំពត ត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៥,០ ក្នុងនោះ តំបន់រណបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង១,៥ តំបន់បន្ទាប់ពីតំបន់រណបត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង២,៥ និងតំបន់បន្ទាប់ពីតំបន់នេះទៀតត្រូវបានកំណត់សន្ទស្សន៍ប្រើប្រាស់ដីអតិបរមាស្មើនឹង៣,៥។

### ៤.២-យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍

យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ក្រុងកំពត មានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការអភិវឌ្ឍទេសចរណ៍តំបន់ ក៏ដូចជានៅទូទាំងប្រទេសកម្ពុជា។ ក្រុងកំពតមានសក្តានុពលទេសចរណ៍ ជាច្រើនដូចជា សំណង់ស្ថាបត្យកម្មបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រផ្នែកកណ្តាលក្រុង តំបន់ទេសចរណ៍ ធម្មជាតិតាមដងព្រែក ឆ្នេរសមុទ្រ និងសហគមន៍ទេសចរណ៍ និងតំបន់រមណីយដ្ឋានទេសចរណ៍នានានៅក្រៅក្រុងកំពតតាមស្រុក ក្នុងខេត្តជាច្រើនទៀតដែលត្រូវបានទទួលស្គាល់ថាជាតំបន់ S4 ( Sea: សមុទ្រ Sun: ព្រះអាទិត្យ Sand: ខ្សាច់ Salt: អំបិល) ហើយជាគោលដៅទេសចរណ៍ពេញនិយម ល្អឯកតែមួយគត់ សម្រាប់ការស្នាក់នៅ និងលម្ហែកម្សាន្ត។ ជាក់ស្តែងចំនួនភ្ញៀវទេសចរអន្តរជាតិមកទស្សនាខេត្តកំពតក្នុងឆ្នាំ ២០០៩ មានចំនួន៩៩៨ ០០០ នាក់ និងក្នុងឆ្នាំ២០១៦ មានចំនួន២ ១៥៥ ៣៨៦ នាក់បានកើនឡើង២ ដង។ ចំណែកចំនួនភ្ញៀវទេសចរក្នុងស្រុកក្នុងឆ្នាំ២០០៩ មាន ចំនួន១ ២៧៩ ៣០៦ នាក់ និងក្នុងឆ្នាំ២០១៦ មានចំនួន ២ ៩២៧ ៩១៥ នាក់បានកើនឡើង២,២៨ ដង។

តំបន់ឆ្នេរដែលស្ថិតនៅក្នុងច្រករបៀងទេសចរណ៍ភាគខាងត្បូង ជាតារាវៈនាទិសនិរតីនៃប្រទេសកម្ពុជា រួមមានខេត្តកំពត កែប ព្រះសីហនុ និងខេត្តកោះកុង ដែលជាប៉ូលទេសចរណ៍ដ៏មានសារៈសំខាន់។ បច្ចុប្បន្ន ខេត្តកំពតបាននឹងបំពេញតួនាទីស្នូលក្នុងការជម្រុញការអភិវឌ្ឍទេសចរណ៍តំបន់ឆ្នេរ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍ផ្នែកឯកជនរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។ គ្រប់ទីកន្លែងដែលមានសក្តានុពលទេសចរណ៍វប្បធម៌ និងធម្មជាតិ ត្រូវយកចិត្តទុកដាក់រៀបចំប្រែក្លាយជាគោលដៅទេសចរណ៍ ផ្សព្វផ្សាយទាក់ទាញភ្ញៀវទេសចរទៅទស្សនា និងរៀបចំយន្តការគ្រប់គ្រង និងអភិវឌ្ឍន៍នៅនឹងកន្លែង ក្នុងនោះការប្រមូលផ្តុំចងក្រងជាសហគមន៍ទេសចរណ៍ ដោយផ្តល់លទ្ធភាព សមត្ថភាព ចំណេះដឹង និងផលប្រយោជន៍ជូនប្រជាជនមូលដ្ឋាន គឺជាអាទិភាព។

យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ក្រុងកំពត រួមមាន÷

**៤.២.១-តំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌ វប្បធម៌ប្រវត្តិសាស្ត្រផ្នែកកណ្ដាលក្រុង**

- រៀបចំអភិវឌ្ឍន៍ផលិតផលទេសចរណ៍ វប្បធម៌ ប្រវត្តិសាស្ត្រ និងការរៀបចំទេសចរណ៍កែច្នៃជាពិសេសតាមលំនៅឋានបេតិកភណ្ឌ
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការការពារសំណង់ស្ថាបត្យកម្មបេតិកភណ្ឌវប្បធម៌ ដោយផ្សារភ្ជាប់នឹងទេសភាពវប្បធម៌ធម្មជាតិភ្នំបូកគោ
- រៀបចំសណ្ដាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតរថយន្ត សញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- ពង្រីកទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ដោយសហការជាមួយផ្នែកឯកជនក្នុងការផលិតឯកសារផ្សព្វផ្សាយ និងសកម្មភាពផ្សព្វផ្សាយទាំងក្នុង និងក្រៅប្រទេស
- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ទេសចរណ៍ទាំងមូល ហើយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អនុតំបន់ និងតំបន់
- សហការជាមួយក្រុមហ៊ុនភាពយន្ត និងក្រុមហ៊ុនផ្សាយពាណិជ្ជកម្មដើម្បីរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានានៅក្នុងខេត្ត
- ឃោសនាផ្សព្វផ្សាយ និងទាក់ទាញឱ្យមានការធ្វើដំណើរតាមផ្លូវគោក ផ្លូវដែក និងផ្លូវទឹកតាមទូកទេសចរណ៍មកខេត្តកំពតឱ្យបានច្រើន
- ពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេសត្រូវបណ្ដុះបណ្ដាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ ឬសង្គ្រោះបឋម សន្តិសុខការពារតាមរមណីយដ្ឋាន ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់
- បង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងផលិតផលទេសចរណ៍ រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិពរណ៍ផលិតផលក្នុងស្រុក
- រៀបចំបែងចែកតំបន់សណ្ឋាគារ ភោជនីយដ្ឋាន រមណីយដ្ឋាន ផ្សាររាត្រី លំនៅឋានទេសចរណ៍ បង្កលភាពងាយស្រួលដល់ភ្ញៀវទេសចរ
- កែលម្អ និងរៀបចំផ្លូវមេ ផ្លូវដឹកជញ្ជូន ផ្លូវសម្រាប់យានយន្ត ផ្លូវថ្មើរជើង និងបណ្ដាញ បៃតងធានាបាននូវសោភ័ណភាព វប្បធម៌ សន្តិសុខ សណ្ដាប់ធ្នាប់ សុវត្ថិភាព និងគុណភាពបរិស្ថានល្អសម្រាប់មនុស្សទាំងអស់គ្នា
- កែលម្អ និងរៀបចំផ្សារ កន្លែងលក់វត្ថុអនុស្សាវរីយ៍ កន្លែងផ្ដល់សេវាកម្ម និងព័ត៌មានទេសចរណ៍

- ធ្វើសមាហរណកម្មផែនការអភិវឌ្ឍទេសចរណ៍ទៅក្នុងផែនការអភិវឌ្ឍទីក្រុងដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព
- ធានាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសាធារណៈ ពិសេសនៅតាមកន្លែងកម្សាន្ត និងកន្លែងស្នាក់នៅ
- លើកកម្ពស់អនាម័យចំណីអាហារ និងប្រព័ន្ធត្រួតពិនិត្យស្តង់ដា។

### ៤.២.២-តំបន់ទេសចរណ៍ធម្មជាតិ

- ជំរុញការរៀបចំអភិវឌ្ឍន៍ផលិតផលទេសចរណ៍ធម្មជាតិតាមដងព្រៃក និងឆ្នេរសមុទ្រ និងការរៀបចំទូកទេសចរណ៍សម្រាប់ដំណើរកម្សាន្ត គយគន់ព្រៃលិចទឹក ព្រៃកោងកាង ស្រែអំបិល ឆ្នេរខ្សាច់ ព្រះអាទិត្យលិច និងមើលសត្វអំពិលអំពែកពេលយប់
- រៀបចំចងក្រងសហគមន៍ ដែលមានសក្តានុពលផ្នែកទេសចរណ៍ អភិវឌ្ឍន៍ទេសចរណ៍ស្នាក់នៅ និងលក់ផលិតផល ក្នុងតំបន់រមណីយដ្ឋាន
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្ស និងការការពារធនធាន និងជីវចម្រុះក្នុងព្រៃក និងសមុទ្រ
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ ចំណតទូក ផ្លាកសញ្ញាបង្ហាញផ្លូវទេសចរណ៍ និងប្រព័ន្ធការពារសុវត្ថិភាព
- បណ្តុះបណ្តាលមន្ត្រីជំនាញ ដើម្បីពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬមធ្យោបាយសង្គ្រោះបឋម និងត្រូវមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់។

### ៤.២.៣-ខ្សែទស្សនាកម្សាន្ត ផលិតផល ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍

- រៀបចំ និងបង្កើតខ្សែទស្សនាកម្សាន្តទេសចរណ៍
- កែលម្អ និងបង្កើតផលិតផលទេសចរណ៍
- កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍។

### ៤.២.៤-ការអភិវឌ្ឍធនធានមនុស្ស

- បណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមស្តង់ដារទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិវឌ្ឍន៍ទេសចរណ៍
- រៀបចំបង្កើតគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈឯកទេសទេសចរណ៍
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈលើវិស័យទេសចរណ៍
- ចលនាផ្នែកឯកជន ឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្ម។

## ៤.៣-យុទ្ធសាស្ត្រអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

ព្រែកកំពតបានហូតកាត់ក្រុងកំពត និងបានចែកក្រុងកំពតជា៣ផ្នែកគឺ ត្រើយខាងកើត មានសង្កាត់កំពង់កណ្ដាល កំពង់បាយ និងសង្កាត់ក្រាំងអំពិល ត្រើយខាងលិច មានសង្កាត់អណ្ដូងខ្មែរ និងត្រើយខាងត្បូង មានសង្កាត់ត្រើយកោះ។ ផ្នែកទាំង៣នេះ បានតភ្ជាប់គ្នាវិញដោយស្ពានចំនួន៤ គឺស្ពានអយស្ម័យយានចំនួន១ ស្ពានបាឡេចំនួន ១ ស្ពានថ្មបុរាណចំនួន ១ និងស្ពានថ្មថ្មីចំនួន ១ និងមានផ្លូវជាតិសំខាន់២ឆ្លងកាត់គឺផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៣៣។ ហេដ្ឋារចនាសម្ព័ន្ធក្រុងកំពតត្រូវពង្រឹង និងលើកកម្ពស់សម្រាប់វិស័យ ទេសចរណ៍ សេដ្ឋកិច្ច បរិស្ថាន និងសង្គម រួមមាន÷

### ៤.៣.១-អ័ក្សអភិវឌ្ឍន៍ភស្តុភារកម្មទេសចរណ៍- ពាណិជ្ជកម្ម តាមផ្លូវជាតិ

- ពង្រីកទទឹងផ្លូវជាតិលេខ៣ និងផ្លូវជាតិលេខ៣៣
- សាងសង់ផ្លូវក្រវាត់ក្រុង
- សាងសង់ស្ពានបន្ថែមដែលមិនប៉ះពាល់ដល់តំបន់សំណង់បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ ហើយអាចឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូន និងចរាចរណ៍។

### ៤.៣.២-អ័ក្សអភិវឌ្ឍន៍ភស្តុភារកម្ម- ឧស្សាហកម្ម តាមផ្លូវអយស្ម័យយាន

ផ្លូវអយស្ម័យយានដែលតភ្ជាប់រវាងខេត្តកំពត ទៅកំពង់ផែក្រុងព្រះសីហនុ និងទៅរាជធានីភ្នំពេញត្រូវបានស្ដារឡើងវិញ។ ផ្លូវអយស្ម័យយាននេះ គួរធ្វើទំនើបកម្មបន្ថែម ដើម្បីក្លាយជាមធ្យោបាយជំនួសឱ្យការដឹកជញ្ជូនតាមរថយន្តដឹកអ្នកដំណើរ អ្នកទេសចរ និងទំនិញ ប្រកបដោយប្រសិទ្ធភាព កាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន កាត់បន្ថយការចំណាយ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងកាត់បន្ថយពេលវេលា។

### ៤.៣.៣-អ័ក្សអភិវឌ្ឍន៍គាំទ្រពាណិជ្ជកម្មតាមព្រំដែន

កែលម្អបណ្ដាញផ្លូវគមនាគមន៍ និងការធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីលើកកម្ពស់ការអភិវឌ្ឍតំបន់ពាណិជ្ជកម្ម និងការដឹកជញ្ជូនតាមច្រកទ្វារព្រំដែនអន្តរជាតិ រវាងប្រទេសវៀតណាម និងប្រទេសថៃ ឆ្លងកាត់ខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង ឱ្យកាន់តែមានប្រសិទ្ធភាព។

### ៤.៣.៤-ផ្លូវថ្នល់

យុទ្ធសាស្ត្រស្ដារអភិវឌ្ឍន៍ និងការពារបណ្ដាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធក្រុងកំពតមានដូចខាងក្រោម÷

- ស្ថាបនាផ្លូវវាងក្រុង ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍
- ជួសជុលស្ពានចាស់ ពង្រីកផ្លូវនៅក្នុងក្រុង សាងសង់ជាផ្លូវបេតុង និងជាផ្លូវកៅស៊ូ

- រៀបចំកសាង និងកែលម្អផ្លូវស្របតាមបណ្ដោយព្រែកកំពត និងបណ្ដាញផ្លូវក្នុងទីក្រុងឱ្យមានគុណភាព និងសោភ័ណភាព ស្របតាមគោលការណ៍អភិវឌ្ឍន៍បៃតង
- រៀបចំនិងកែលម្អចំណតរថយន្តសាធារណៈឱ្យស្របតាមបទដ្ឋានទីក្រុងទេសចរណ៍ស្អាត
- សាងសង់ផ្លូវក្រវាត់ក្រុងខាងក្នុងឱ្យមានទទឹងប្រវែង២៨ ម៉ែត្រ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ តំបន់ផ្សារសាមគ្គី ដោយសាងសង់ជាផ្លូវឆ្លោះអំពីបេតុង ចេញពីចំណុចផ្លូវជាតិលេខ៣ ឆ្ពោះមកផ្លូវបេតុងម៉ាកេងស្របនឹងផ្លូវអាយស្វ័យយានខាងត្បូង រហូតដល់គល់ស្ពានថ្មថ្មីក្នុងសង្កាត់កំពង់បាយ
- សាងសង់បណ្ដាញផ្លូវក្រវាត់ក្រុងខាងក្រៅឱ្យមានទទឹងប្រវែងយ៉ាងតិច៥០ ម៉ែត្រ និងសាងសង់ស្ពានចំនួន៣តភ្ជាប់តំបន់ស្នូលនគរូបនីយកម្មឱ្យមានទំនាក់ទំនងប្រសើរជាងមុន ដើម្បីកាត់បន្ថយនូវពេលវេលាធ្វើដំណើរ និងដឹកជញ្ជូន។ ទីតាំងទី១ ចេញពីឃុំជុំគ្រៀលតភ្ជាប់ទៅសង្កាត់ត្រើយកោះ ទីតាំងទី២ ចេញពីសង្កាត់ត្រើយកោះតភ្ជាប់ទៅឃុំបឹងទូក និងទីតាំងទី៣ ចេញពីសង្កាត់អណ្ដូងខ្មែរតភ្ជាប់ទៅឃុំកំពង់ក្រែង
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងផ្លូវក្រវាត់ក្រុងខាងក្រៅ តភ្ជាប់ទីក្រុងចាស់ ទៅកាន់ភាគខាងត្បូងក្រុងកំពត ស្របទៅតាមគោលនយោបាយអភិវឌ្ឍន៍របស់ខេត្តកំពត ក្នុងការបង្កើតឱ្យមានតំបន់រមណីយដ្ឋានកំពតថ្មី ជាគោលដៅទេសចរណ៍ដ៏ទាក់ទាញ សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិនាពេលអនាគត និងពង្រីកតំបន់រដ្ឋបាលក្រុងកំពតទៅកាន់ឃុំជុំគ្រៀល ឃុំបឹងទូក ឃុំកំពង់ក្រែង និងឃុំត្រពាំងធំ របស់ស្រុកទឹកឈូ។

### ៤.៣.៥-ផ្លូវទឹក

- ការពារនិងកែលម្អអតីតកំពង់ផែទំនិញ និងផែទូកនេសាទកំពង់កណ្ដាលបច្ចុប្បន្ន
- ស្ដារព្រែកកំពត និងឃ្លងសមុទ្រឱ្យបានជ្រៅងាយស្រួលដល់ការដឹកជញ្ជូន
- រៀបចំ និងអភិវឌ្ឍកំពង់ផែថ្មី នៅឃុំជុំគ្រៀល ស្រុកទឹកឈូ ជាកំពង់ផែពាណិជ្ជកម្ម គាំទ្រការអភិវឌ្ឍខេត្ត និងក្រុង
- រៀបចំនិងសាងសង់កំពង់ផែទេសចរណ៍អន្តរជាតិនៅឃុំជុំគ្រៀល ស្រុកទឹកឈូ និងមធ្យោបាយដឹកជញ្ជូនអ្នកដំណើរកម្សាន្តតាមព្រែកកំពត
- រៀបចំប្រព័ន្ធដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនស្របតាមតម្រូវការ។

### ៤.៣.៦-ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- ធ្វើឱ្យប្រសើរឡើង និងអភិវឌ្ឍវិស័យថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម

- ពង្រីកបន្ថែមបណ្តាញអគ្គិសនីឱ្យដល់គ្រប់ភូមិ
- បន្ត និងជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់អគ្គិសនីដើរដោយថាមពលពន្លឺព្រះអាទិត្យ
- ជំរុញលើកទឹកចិត្តឱ្យប្រើប្រាស់យានយន្តប្រើអាគុយ។

**៤.៣.៧- ហេដ្ឋារចនាសម្ព័ន្ធសង្គម និងវប្បធម៌**

- ស្តារ និងរៀបចំលម្អសាធារណៈ ផ្ទៃបៃតង សួនសាធារណៈ មជ្ឈមណ្ឌលវប្បធម៌ និងសាសនា ដល់មនុស្សគ្រប់វ័យ រួមមាន កុមារ យុវជន ស្ត្រី បុរស មនុស្សវ័យចាស់ និងជនពិការ ឱ្យទទួលបាននូវសេវាប្រកបដោយសមធម៌
- រៀបចំឱ្យមានផ្លូវថ្មើរជើង ផ្លូវសម្រាប់ជនពិការ បង្គន់អនាម័យសម្រាប់ជនពិការនៅតាមទីសាធារណៈ អគារសាធារណៈនិងកន្លែងផ្តល់សេវាកម្មផ្សេងៗ
- រៀបចំឱ្យមានសាលារៀន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រប់កម្រិត តាមភូមិ សង្កាត់ ក្នុងក្រុងកំពត ស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងបទដ្ឋានបច្ចេកទេសរបស់ក្រសួងអប់រំ យុវជននិងកីឡា និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រៀបចំ កែលម្អ និងពង្រីកសេវាកម្មសុខាភិបាលនៅគ្រប់កម្រិត មានជាអាទិ៍ ប៉ុស្តិ៍សុខភាព កន្លែងសង្គ្រោះបន្ទាន់ មណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក មន្ទីរពេទ្យ ឱសថស្ថាន នៅតាមសង្កាត់ និងក្នុងក្រុងស្របតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងសុខាភិបាល
- បង្កើតមជ្ឈមណ្ឌលថែទាំសុខភាព ថែទាំវេជ្ជសាស្ត្រ និងខ្យល់អាកាសធម្មជាតិ។

**៤.៣.៨- ការផ្គត់ផ្គង់ទឹកស្អាត**

**ក)- ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ក្រុង**

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ត្រូវបានបង្កើតឡើងក្នុងក្រុងកំពត សង្កាត់អណ្តូងខ្មែរ ។ ប្រព័ន្ធដែលមានស្រាប់ ត្រូវកែលម្អ និងពង្រីកបន្ថែមដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ តម្រូវការបន្ទាន់បំផុតសម្រាប់ការកែលម្អការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ក្រុងកំពត គឺមានដូចខាងក្រោម៖

- សិក្សាពីជលសាស្ត្រ និងត្រួតពិនិត្យតាមដាន ដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹក
- សិក្សាប្រភពទឹកផ្សេងៗដើម្បីផ្គត់ផ្គង់ទឹកស្អាតសម្រាប់តំបន់កណ្តាលក្រុង និងជាយក្រុង
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការផ្សេងៗដើម្បីការពារប្រភពផ្គត់ផ្គង់ទឹកបណ្តាលមកពីការអភិវឌ្ឍក្រុង
- ស្តារឡើងវិញ និងការដោះដូរបំពង់ទឹកចាស់ៗ ដើម្បីកាត់បន្ថយការលេចធ្លាយ និងបង្កើនគុណភាពទឹក
- ពង្រីកបណ្តាញចែកចាយទឹក ដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុន និងដើម្បីបង្កើនប្រាក់ចំណូល

- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញចែកចាយទឹក ដើម្បីធានាការផ្គត់ផ្គង់ស្របតាមការរីកចម្រើន និងការប្រើប្រាស់
- បន្តពង្រឹងសមត្ថភាព និងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកស្របតាមបទដ្ឋានបច្ចេកទេស។

**២)-ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជាយក្រុង**

- ការពារប្រភពទឹកធម្មជាតិ
- ស្តារ និងកែលម្អអាងស្តុកទឹក និងបណ្តាញចែកចាយទឹកដែលមានស្រាប់ ដើម្បីអភិវឌ្ឍន៍និងផ្គត់ផ្គង់ទឹកស្អាត
- សិក្សា និងសាងសង់អាងស្តុកទឹក និងពង្រីកបណ្តាញចែកចាយទឹកបន្ថែម។

## ៤.៤-យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក

ដើម្បីធ្វើឱ្យប្រជាជនមូលដ្ឋានទទួលបានផលប្រយោជន៍ពីវិស័យទេសចរណ៍ច្រើន ចាំបាច់ត្រូវ÷

- ថែរក្សា និងការពារដីស្រែ ចំការ ដីផលិតអំបិល ជម្រុញការអភិវឌ្ឍវិស័យកសិកម្មបែបទំនើបឱ្យមានប្រសិទ្ធភាព និងចីរភាព
- ជំរុញការធ្វើកសិកម្មសរីរាង្គ ដោយប្រើជីធម្មជាតិសម្រាប់ការប្រើប្រាស់ក្នុងតំបន់ និងនាំចេញ ដោយបង្កើនគុណភាពផលិតផល និងផ្សព្វផ្សាយអំពីផលិតផលផ្សេងៗ ដែលផលិតដោ កសិករនៅមូលដ្ឋាន ឬអ្នកជំនួញក្នុងស្រុក ក្រោមនិមិត្តសញ្ញាសម្គាល់ភូមិសាស្ត្រទំនិញ “កំពត” ធុរេន ដូង ម្រេច អំបិល និងនំចាក ស្កត្នោត ទឹកត្រី សម្រាប់លក់ទៅឱ្យភ្ញៀវទេសចរក្នុងស្រុក និងក្រៅស្រុកក្នុងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បង្កបរិយាកាសល្អ លើកទឹកចិត្ត និងជម្រុញការវិនិយោគក្នុងស្រុក និងក្រៅស្រុកលើវិស័យកសិកម្ម និងវារីវប្បកម្ម ដោយផ្អែកលើធនធានសមុទ្រ ដើម្បីគាំទ្រដល់វិស័យទេសចរណ៍ និងអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងក្រុង
- ពង្រីកការកែច្នៃធនធានសមុទ្រ ដើម្បីលក់ជូនភ្ញៀវទេសចរ
- ពង្រឹង និងពង្រីកធនាគារក្តាម
- ធ្វើសមាហរណកម្មសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍ដើម្បីលើកកម្ពស់ទំនិញសហគមន៍តាម រយៈភូមិមួយផលិតផលមួយ និងបង្កើតភូមិផលិតកម្មបម្រើភ្ញៀវទេសចរ និងរៀបចំដំណើរកម្សាន្ត
- អភិវឌ្ឍផលិតផលកសិកម្មតាមតម្រូវការទីផ្សារទេសចរណ៍
- សិក្សាទីផ្សារ និងផ្សព្វផ្សាយផលិតផលកសិកម្មដែលមានគុណភាពល្អក្នុងស្រុក

- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានអំពីស្តង់ដារបច្ចេកទេសកសិកម្មដល់ប្រជាជន
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីលុបបំបាត់ឱ្យបាននូវការធ្វើកសិកម្មដែលបំផ្លាញធនធានធម្មជាតិ ប្រើប្រាស់ជី និងថ្នាំគីមី មិនគោរពតាមស្តង់ដាបច្ចេកទេស
- អភិវឌ្ឍធនធានមនុស្សដោយជំរុញការបណ្តុះបណ្តាលជំនាញដល់កសិករ ដោយអនុវត្តតាមស្តង់ដាកសិកម្ម និងចលនាផ្នែកឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋាន។

## ៤.៥-យុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមកិច្ច

- ដោះស្រាយសំណង់បណ្តោះអាសន្ននៅលើដី ដីចំណីឆ្នេរសមុទ្រ និងដីចំណីផ្លូវដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ
- យកចិត្តទុកដាក់ជួយដល់ប្រជាពលរដ្ឋក្រីក្រ និងជនងាយរងគ្រោះជាពិសេសប្រជានេសាទដែលទទួលរងការគំរាមកំហែងពីគ្រោះធម្មជាតិ
- ជម្រុញឱ្យសហគមន៍ទទួលបានការគាំទ្រ និងលើកទឹកចិត្តពីផ្នែកសាធារណៈនិងសង្គមស៊ីវិល
- ជម្រុញការអភិវឌ្ឍសមត្ថភាពរបស់ប្រជាជននៅជនបទ ឱ្យមានជំនាញវិជ្ជាជីវៈដែលអាចប្រកបមុខរបរបាន ដើម្បីលើកកម្ពស់កម្រិតជីវភាព
- សិក្សាលទ្ធភាព និងរៀបចំគម្រោងសម្បទានដីសង្គមកិច្ចសម្រាប់ប្រជាជនក្រីក្រក្នុងក្រុង និងប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្នគ្រប់កន្លែង ជាពិសេសក្នុងតំបន់ជាប់ព្រែក និងឆ្នេរសមុទ្រ។

## ៤.៦-យុទ្ធសាស្ត្រការពារបរិស្ថាន និងធនធានធម្មជាតិ

### ៤.៦.១-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

ទីកន្លែងទុកដាក់សំរាមនៅក្នុងក្រុងកំពតបច្ចុប្បន្នស្ថិតនៅលើដីរាបស្មើ ប្រហែល១០ គីឡូម៉ែត្រ ខាងជើងទីក្រុងកំពតក្នុងស្រុកទឹកឈូសម្ងាយ៣ គីឡូម៉ែត្រពីផ្លូវជាតិលេខ៣ តាមផ្លូវលំ។ ការធ្វើដំណើរចូលទៅកន្លែងចាក់សំរាមជួបការលំបាក ខណៈដែលមានភ្លៀងធ្លាក់និងស្ថិតក្នុងរដូវវស្សា។ ទីតាំងនេះមានផ្ទៃដីទំហំ១៧.២ ហិកតា ហើយត្រូវបានបែងចែកជាបីផ្នែក សម្រាប់ការប្រើប្រាស់ផ្សេងៗគ្នា។ សេវាប្រមូលសំរាមក្នុងពេលបច្ចុប្បន្នត្រូវបានផ្តល់ឱ្យក្រុមហ៊ុនឯកជនមួយឈ្មោះហ្គាអ៊ា ដែលដឹកសំរាមយកទៅចាក់នៅទីលានចាក់សំរាមពី១៥ ទៅ២០ តោន/ថ្ងៃ។ យូរៗម្តង គំនរសំរាមត្រូវភ្លើងឆេះ ដែលបង្កដោយអ្នករើសសំរាម។ ដូចនេះដើម្បីគ្រប់គ្រង សំណល់រឹង ឱ្យបានល្អ ត្រូវមានយន្តការ និងបទដ្ឋានបច្ចេកទេសដូចខាងក្រោម÷

- រៀបចំទំនប់ព័ទ្ធជុំវិញទីតាំងដី
- ត្រួតពិនិត្យទឹកក្រោមដី
- រៀបចំជាផ្នែកៗ កន្លែងសំអាតកំទេចកំទីសំរាម កន្លែងស្តុក គំរបដី ការលុបកាកសំណល់
- គ្រប់គ្រងការរើសសំរាម

- បង្កើនការផ្សព្វផ្សាយដល់ប្រជាជនពីការញែកសំរាម (ដូចដែលបានអនុវត្តរួចមកហើយ) ហើយអាចពង្រីកបន្ថែមនៅតាមសាលានិង និងទីសាធារណៈផ្សេងៗទៀត
- ផ្តល់លេខកូដធុងញែកសំរាមតាមពិណ ឬថង់សំរាមស្រាលៗដល់អ្នករើសសំរាម
- ជំរុញការសហការវាងកន្លែងគរសំរាមមានស្រាប់ ដើម្បីញែក និងកាត់បន្ថយបរិមាណសរីរាង្គនៃសំណល់
- អ្នករើសសំរាមអាចទទួលបានវគ្គបណ្តុះបណ្តាល បង្កើនចំណេះដឹងស្វែងយល់ពីកាកសំណល់ដើម្បីផលិតសម្ភារៈ ធ្វើឱ្យការងារកាន់តែល្អប្រសើរសម្រាប់អ្នករើសសំរាមជាមួយនឹងទីកន្លែងធ្វើការសមរម្យ នៅក្នុងរោងដែលមានខ្យល់ចេញចូលល្អ ដើម្បីចៀសវាងបានពីតំបន់មុខសញ្ញាគ្រោះថ្នាក់ផ្សេងៗ
- ផ្តល់សម្ភារៈធ្វើការប្រកបដោយសុវត្ថិភាព និងទុនសម្រាប់ការបណ្តុះបណ្តាល
- បង្កើតយន្តការ និងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងនិងខេត្តកំពត
- រៀបចំមធ្យោបាយប្រមូលសំណល់រឹង និងរៀបចំទីតាំងសម្រាប់ទុកដាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេស និងស្តង់ដាទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង
- ជំរុញឱ្យមានការអនុវត្តគោលការណ៍ ការកាត់បន្ថយការប្រើប្រាស់ឡើងវិញ និងការកែច្នៃ លើការគ្រប់គ្រងសំណល់រឹង បង្កើតគម្រោងជីកំប៉ុស្តិ៍
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់វិស័យឯកជន និងសាធារណៈ។

### ៤.៦.២-ក្របខណ្ឌយុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

ប្រព័ន្ធលូបង្ហូរនៅក្នុងខេត្តកំពតត្រូវបានប្របាច់បញ្ចូលគ្នារវាងគម្រោងទឹកស្អុយ និងគម្រោងទឹកស្អាតនៅក្រៅ ហើយដែលបង្ហូរចូលក្នុងព្រែកទឹកឈ្ងផ្ទាល់ តាមលូធំចំនួន៦ ចំណែកលូធំ២ផ្សេងទៀតបានហូរឆ្លងកាត់អាងប្រព្រឹត្តិកម្មចម្រោះសិនទើបបង្ហូរចូលព្រែក ។ ជាពិសេស ក្នុងចំណោមបំពង់បង្ហូរទឹកស្អុយទាំងនោះ យើងឃើញលូទឹកស្អុយ និងស្អាត ហូរចូលប្រព័ន្ធលូសាធារណៈជាមួយគ្នា។ ជំនន់តាមរដូវកាល កើតមានច្រើននៅក្នុងក្រុង ក្នុងអំឡុងរដូវវស្សា ដែលបណ្តាលមកពីធម្មជាតិ និងពីមនុស្ស។ ប្រព័ន្ធលូទឹកស្អុយនេះអាចនឹងហៀរចូលទីទំនាបពេលដែលកម្រិតទឹកព្រែកឡើងខ្ពស់ ដែលពុំមានទំនាញអាចទាញទឹកស្អុយចេញពីក្រុងបាន ដែលអាចបង្កឱ្យមានជន់លិច និងមានបញ្ហាដល់សុខភាព ពិសេសតំបន់ផ្សារសាមគ្គី។ ម្យ៉ាងទៀតដោយសារការរីកចម្រើនផ្នែកនគរូបនីយកម្ម នៅផ្នែកកណ្តាលក្រុង ផ្នែកខាងកើត ខាងលិច និងផ្នែកខាងត្បូងនៃព្រែកកំពត ធ្វើឱ្យសំណល់រាវដែលចេញមកពីការប្រើប្រាស់ផ្សេងៗមានការកើនឡើង។ ដូចនេះដើម្បីគ្រប់គ្រងសំណល់រាវឱ្យបានល្អ ត្រូវមានបទដ្ឋានបច្ចេកទេស និងយន្តការដូចខាងក្រោម÷

- រៀបចំ និងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវចម្រោះទឹកឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលបំពង់លូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈត្រូវមានអាងប្រព្រឹត្តិកម្ម និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថាន និងអនាម័យ ដើម្បីធានាបាននិរន្តរភាពតំបន់បេតិកភណ្ឌ ដែលជាតារាវៈនៅទិសនីរតី។

### ៤.៦-៣.ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

ការបែងចែកតំបន់ប្រើប្រាស់ដី សម្រាប់ការការពារបរិស្ថានមានដូចខាងក្រោម÷

- តំបន់កណ្តាលក្រុង (តំបន់បេតិកភណ្ឌវប្បធម៌និងប្រវត្តិសាស្ត្រ)
- តំបន់ព្រៃឈើ ភ្នំ
- តំបន់ព្រៃលិចទឹក និងព្រៃកោងកាង
- តំបន់ធនធានទឹក (សមុទ្រ ព្រែក អូរ ប្រឡាយ ស្ទឹង បណ្តាញផ្លូវទឹក)
- តំបន់ស្រែអំបិល
- តំបន់សហគមន៍។

### ៤.៦.៤-វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារ និងថែរក្សា អគារបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ តំបន់ទេសភាពវប្បធម៌ ភ្នំ ព្រៃឈើ បឹង អូរ និងប្រព័ន្ធបណ្តាញផ្លូវទឹក ស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារ និងថែរក្សាតំបន់ព្រៃលិចទឹក ព្រៃកោងកាង ដើម្បីធានាប្រព័ន្ធអេកូឡូស៊ីព្រៃលិចទឹកឱ្យមានផលិតភាពខ្ពស់ និងមានសារៈសំខាន់នៅក្នុងអាយុកាលនៃជីវចម្រុះព្រែក កំពត និងឆ្នេរសមុទ្រ ដែលជាកន្លែងពង-កូន ឬកន្លែងរកចំណីសម្រាប់ធនធានវារិជាត និងប្រភេទត្រី
- ការពារ និងថែរក្សាព្រៃតំបន់ឆ្នេរ និងព្រៃក្នុងតំបន់ទីជម្រាល ដើម្បីធានាការគ្រប់គ្រង បរិស្ថានប្រកបដោយចីរភាព
- កាត់បន្ថយការបំពុលខ្យល់ដោយសារម៉ាស៊ីន តាមរយៈការផ្គត់ផ្គង់អគ្គិសនីរដ្ឋឱ្យបានច្រើនបំផុតក្នុងតំបន់ក្រុង
- ការលើកកម្ពស់មធ្យោបាយដឹកជញ្ជូនដែលមិនបំពុលបរិស្ថានក្នុងតំបន់កណ្តាលក្រុង
- ពង្រីក និងជំរុញឱ្យមានការប្រើប្រាស់ប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីរបស់ក្រុង

- លើកកម្ពស់ចំណេះដឹងបរិស្ថានដល់ប្រជាជន និងរៀបចំឱ្យមានមូលនិធិសម្រាប់ថែទាំបរិស្ថាន ដោយមានការចូលរួមពីវិស័យឯកជន។

## ៤.៧-យុទ្ធសាស្ត្របង្ការទប់ស្កាត់គ្រោះមហន្តរាយ

ខេត្តកំពត ជាខេត្តមួយស្ថិតនៅតំបន់ខ្ពង់រាប និងវាលទំនាប ដែលមានផ្នែកខ្លះស្ថិតនៅជាប់តំបន់ភ្នំ និងផ្នែកខ្លះទៀតនៅជាប់សមុទ្រ ដែលជាហេតុធ្វើឱ្យខេត្តកំពត តែងតែទទួលរងគ្រោះដោយទឹកជំនន់ រាំងស្ងួត និងខ្យល់កន្ត្រាក់។ បញ្ហានេះបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាពលរដ្ឋដូចជា ធ្វើឲ្យសុខភាពមិនល្អ ខ្វះខាតទឹកប្រើប្រាស់ ទឹកមិនស្អាត កើតជំងឺរាគរូស ខូចខាតដំណាំកសិកម្ម ប៉ះពាល់ដល់សេដ្ឋកិច្ច ជីវភាព មុខរបរប្រចាំថ្ងៃ ខូចខាតទ្រព្យសម្បត្តិ ផ្ទះសំបែង និងខូចខាតហេដ្ឋារចនាសម្ព័ន្ធផ្សេងៗជាច្រើនទៀត។ ក្រុងកំពត មានសង្កាត់ត្រើយកោះ និងសង្កាត់អណ្តូងខ្មែរ ជាតំបន់តែងតែទទួលរងគ្រោះដោយទឹកជំនន់ រាំងស្ងួត និងខ្យល់កន្ត្រាក់ ស្ថិតក្នុងកម្រិតតំបន់មានហានិភ័យមធ្យម។ ដូចនេះដើម្បីទប់ស្កាត់គ្រោះមន្តរាយទាំងអស់នេះបានទាន់ពេលវេលា ត្រូវមានយន្តការ និងយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម÷

- ការពារធនធានធម្មជាតិ ជីវចម្រុះ ទាំងក្នុងព្រៃក និងតំបន់ឆ្នេរ ដើម្បីរក្សាបានតុល្យភាពបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ដោយមានការដាំដើមឈើ ព្រៃកោងកាងឲ្យបានច្រើន នៅតំបន់លម្ហសាធារណៈ តាមតំបន់ឆ្នេរសមុទ្រ និងតាមលំនៅឋាន
- ត្រូវរៀបចំស្តារព្រែក ស្ទឹង អូរ ប្រឡាយ បឹង ត្រពាំង ទំនប់ទឹក និងបណ្តាញផ្លូវទឹកផ្សេងៗទៀត
- លើកកម្ពស់ប្រសិទ្ធភាពនៃការអភិរក្សការការពារសំណង់ស្ថាបត្យកម្មបេតិកភណ្ឌ និងទេសភាពធម្មជាតិវប្បធម៌ជុំវិញ ដោយសិក្សានិងរៀបចំផែនការគ្រប់គ្រងឱ្យបានត្រឹមត្រូវ
- រៀបចំ ស្តារ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតដោយអង្គភាពរដ្ឋាករស្វយ័តខេត្តកំពតដល់ប្រជាជនក្នុងក្រុងឱ្យបាន១០០% ។
- រក្សាប្រភពទឹកស្អាតពីទឹកឈូ និងស្ទឹងកែវ ដើម្បីធានានូវតុល្យភាពនៃការប្រើប្រាស់ទឹក
- រៀបចំសណ្តាប់ធ្នាប់ ប្រព័ន្ធចរាចរណ៍ និងចំណតរថយន្ត ឱ្យស្ថិតនៅឆ្ងាយពីតំបន់សំណង់ស្ថាបត្យកម្មបេតិកភណ្ឌ កាត់បន្ថយរំញ័ររបស់យានយន្តគ្រប់ប្រភេទដែលអាចប៉ះពាល់ដល់អគារ
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពកាយយកដីភ្នំ និងការកាប់ទន្ទ្រានព្រៃ
- ទប់ស្កាត់ឱ្យខានតែបានចំពោះសកម្មភាពបូមយកដីនៅក្នុងបាតសមុទ្រដែលមិនសមស្របតាមបទដ្ឋានបច្ចេកទេស និងបទដ្ឋានគតិយុត្តជាធរមាន
- រាល់គម្រោងអភិវឌ្ឍន៍តាមបណ្តោយឆ្នេរសមុទ្រ និងកោះចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- ពង្រឹងយន្តការ និងមធ្យោបាយសម្រាប់បង្ការទប់ស្កាត់គ្រោះមហន្តរាយ

- លើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រង និងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រក្រុងកំពត ដោយសិក្សា និងរៀបចំផែនការប្រើប្រាស់ដី ឱ្យបានគ្រប់ជ្រុងជ្រោយ
- អនុវត្តតាមច្បាប់ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ។

### ៤.៨-យុទ្ធសាស្ត្រពង្រឹងការគ្រប់គ្រង និងហិរញ្ញវត្ថុនៅមូលដ្ឋាន

ការគ្រប់គ្រងហិរញ្ញវត្ថុនៅមូលដ្ឋាន គឺជាកត្តាសំខាន់ចាំបាច់ និងជាស្នូលនៃវិស័យទេសចរណ៍ សេដ្ឋកិច្ច អភិវឌ្ឍន៍ក្រុង និងបរិស្ថាន ចាំបាច់ត្រូវ÷

- សម្របសម្រួលស្ថាប័នពាក់ព័ន្ធឱ្យចែករំលែកព័ត៌មានអំពីគម្រោងដែលត្រូវអនុវត្ត និងគម្រោងដែលត្រូវស្នើឡើងក្នុងខេត្ត
- ពង្រឹងមូលដ្ឋានធនធានមនុស្សទាំងនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ជាពិសេសសម្រាប់ការគ្រប់គ្រងអភិវឌ្ឍន៍ និងការត្រួតពិនិត្យគម្រោងសាធារណៈ ការគ្រប់គ្រងដីធ្លី ការប្រមូលពន្ធ។ល។
- ពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការប្រើប្រាស់ដីសាធារណៈ ការផ្តល់លិខិតអនុញ្ញាតសាងសង់ ការចុះបញ្ជីយានយន្ត ការចាក់ដី ការបូមទឹកក្រោមដីរបស់ឯកជន និងការគ្រប់គ្រងបរិស្ថាន
- ពង្រឹងហិរញ្ញវត្ថុនៅមូលដ្ឋាន តាមរយៈការប្រមូលចំណូលនៅមូលដ្ឋាន ការបែងចែកចំណូលរដ្ឋពីវិស័យទេសចរណ៍ និងប្រភពផ្សេងៗទៀត ដល់រដ្ឋបាលមូលដ្ឋាន សម្រាប់ប្រើប្រាស់ជាប្រយោជន៍សាធារណៈ ជាពិសេសសម្រាប់ការជួសជុល និងថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងការលើកកម្ពស់សោភ័ណភាព និងបរិស្ថានទីក្រុង។

## ៥-ផែនការសកម្មភាព

ផ្អែកតាមគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងប្លង់គោលប្រើប្រាស់ដីក្រុងកំពត រដ្ឋបាលខេត្តកំពត រដ្ឋបាលក្រុងកំពត និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធត្រូវអនុវត្តផែនការសកម្មភាពសំខាន់ៗចាំបាច់ដូចខាងក្រោម÷

### ៥.១-ការរៀបចំបទប្បញ្ញត្តិនគរូបនីយកម្ម

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត និងក្រុង ត្រូវរៀបចំបទប្បញ្ញត្តិនគរូបនីយកម្មទាក់ទងនឹងការងារមួយចំនួនដូចខាងក្រោម÷

- ផែនការប្រើប្រាស់ដីក្នុងសង្កាត់ទាំងប្រាំរបស់ក្រុង
- ផែនការប្រើប្រាស់ដីតំបន់ឆ្នេរ និងបទដ្ឋានបច្ចេកទេសសម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍ
- ប្លង់លម្អិតនគរូបនីយកម្មតាមតំបន់នីមួយៗបន្តពីប្លង់គោលប្រើប្រាស់ដី

- តំបន់កម្រិតការសាងសង់ និងតំបន់អាចសាងសង់បាន ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព តុល្យភាព និងប្រសិទ្ធភាព
- ផែនទីកំណត់កម្ពស់អគារ និងសន្ទស្សន៍ប្រើប្រាស់ដីតាមតំបន់
- ផែនទីកំណត់ទីតាំងសំណង់អគារបេតិកភណ្ឌក្រុងកំពត និងប្លង់លម្អិតស្ថាបត្យកម្ម
- ផែនទីកំណត់ទីតាំងលំហសាធារណៈ ឆ្នេរសមុទ្រ ព្រែក ស្ទឹង បឹង ប្រឡាយ ផ្លូវថ្នល់ លំហបៃតង
- ផែនទីកំណត់តំបន់អភិវឌ្ឍជាអាទិភាព។

## ៥.២-ការផ្សព្វផ្សាយ

រៀបចំប្រជុំផ្សព្វផ្សាយប្លង់គោលប្រើប្រាស់ដីក្រុងកំពតនេះ ដល់ក្រុមជំនាញ វិនិយោគិន និងប្រជាពលរដ្ឋ និងតាមរយៈគេហទំព័រ ឬតាមបណ្ដាញសង្គមក្នុងប្រព័ន្ធអេឡិចត្រូនិករបស់រដ្ឋបាលខេត្តកំពត។

## ៥.៣-ការអនុវត្តគម្រោងតាមវិស័យ

គម្រោងសំខាន់ៗដែលត្រូវការចាំបាច់សម្រាប់ការអភិវឌ្ឍក្រុង ទេសចរណ៍ ការដឹកជញ្ជូន កសិកម្ម និងការផ្សព្វផ្សាយផលិតផល ការគ្រប់គ្រងបរិស្ថាន ធនធានទឹកនិងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធលូបង្ហូរទឹកភ្លៀងនិងគ្រប់គ្រងសំណល់រាវ និងការផ្គត់ផ្គង់ថាមពលអគ្គិសនីនិងទូរគមនាគមន៍ មានដូចខាងក្រោម÷

### ៥.៣.១-ការអភិវឌ្ឍក្រុង

- កែលម្អហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្ដាលក្រុង ដូចជាផ្លូវ ភ្លើង ស្ពាន និងសួនច្បារសាធារណៈ
- កសាងផែនការប្រើប្រាស់ដីក្នុងសង្កាត់ទាំង៥ របស់ក្រុង និងប្លង់លម្អិតនគរូបនីយកម្ម
- បណ្ដុះបណ្ដាល និងពង្រឹងសមត្ថភាពធនធានមនុស្សនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ លើការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ធ្វើផែនការអភិវឌ្ឍន៍ និងអភិរក្សតំបន់បេតិកភណ្ឌវប្បធម៌
- ចុះបញ្ជីសារពើភណ្ឌ សំណង់ស្ថាបត្យកម្មប្រវត្តិសាស្ត្រដែលមានតម្លៃសម្រាប់ការអភិរក្សក្នុងក្រុង
- ថែរក្សា ការពារ កែលម្អ និងអភិវឌ្ឍឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ ដីចំណីព្រែក ផ្លូវស្របតាមបណ្ដោយឆ្នេរ និងព្រែក ឱ្យមានអនាម័យ សោភ័ណភាព និងគុណភាពបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា និងសម្រាប់ជាប្រយោជន៍សាធារណៈ ស្របតាមចក្ខុវិស័យក្រុងកំពត ជាគុជបៃតងនៃតំបន់ឆ្នេរសមុទ្រ ធម្មជាតិ វប្បធម៌ និងពាណិជ្ជកម្ម
- ជំរុញផ្សព្វផ្សាយឯកសារគតិយុត្តពាក់ព័ន្ធការងាររៀបចំដែនដីនិងនគរូបនីយកម្ម ការងារគ្រប់គ្រងនិងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកម្ពុជា ពិសេសសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្ដីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំ និងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត។

### ៥.៣.២- ការអភិវឌ្ឍវិស័យទេសចរណ៍

- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទេសចរណ៍
- អភិវឌ្ឍផ្សាររាត្រី
- លើកកម្ពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរវាងរដ្ឋ និងឯកជន
- លើកកម្ពស់សហគមន៍ទេសចរណ៍
- អភិវឌ្ឍ និងលើកកម្ពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ
- បណ្តុះបណ្តាលមគ្គុទេសក៍ទេសចរណ៍ និងការផ្តល់លិខិតអនុញ្ញាត
- សិក្សាលម្អិតអំពីលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន
- ផលិតថង់ធម្មជាតិ ផ្សព្វផ្សាយអំពីសេវាស្នាក់នៅ សេវាហូបចុក សេវាកម្សាន្ត និងសេវាធ្វើដំណើរ
- បោះពុម្ពផែនទីគោលដៅទេសចរណ៍
- បោះពុម្ពសៀវភៅផ្នត់ទេសចរណ៍ជាភាសាខ្មែរ និងភាសាបរទេសចាំបាច់
- ធ្វើផ្លាកសញ្ញា និងផែនទីចង្អុលបង្ហាញទីតាំងតំបន់ទេសចរណ៍ និងសិប្បកម្ម
- ជំរុញការវេចខ្ចប់ និងបិទស្លាកសញ្ញាផលិតផលសិប្បកម្មប្រចាំតំបន់
- ធ្វើតារាងតម្លៃសេវាកម្មកម្សាន្ត សេវាស្នាក់នៅ ហូបចុក និងសេវាធ្វើដំណើរ
- រៀបចំកំពង់ផែទូកទេសចរណ៍សម្រាប់ដឹកភ្ញៀវទេសចរទស្សនាកម្សាន្តតាមដងព្រែកកំពត
- អភិវឌ្ឍពង្រីកក្រុងកំពត ឱ្យមានឆ្នេរខ្សាច់ដ៏ស្រស់ស្អាត សម្រាប់សម្រាក និងលម្ហែកម្សាន្ត
- សហការជាមួយមន្ទីរព័ត៌មានខេត្តរៀបចំកម្មវិធីសន្ទនាមតិតាមវិទ្យុជាតិអំពីទេសចរណ៍ក្នុងក្រុង
- បង្កើតកម្មវិធីចុះសម្ភាសន៍ជាមួយអ្នកផ្តល់សេវា និងអ្នកទទួលសេវា
- សាងសង់មណ្ឌលព័ត៌មានទេសចរណ៍
- ពង្រឹងភ្នាក់ងារគ្រប់គ្រង និងផ្តល់សេវាព័ត៌មានដល់ភ្ញៀវទេសចរ។

### ៥.៣.៣- ការដឹកជញ្ជូន

- កែលម្អស្ពានចាស់ៗពីសម័យមុន និងសាងសង់ស្ពានថ្មីបន្ថែមចំនួន៣ សម្រាប់ឆ្លងកាត់ព្រែកកំពត
- គ្រោងសាងសង់ផ្លូវក្រវាត់ក្រុងថ្មី ដើម្បីតភ្ជាប់នឹងផ្លូវក្រវាត់ក្រុងដែលមានស្រាប់
- កែលម្អបណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០២០
- បន្តសាងសង់បណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០២៥
- បន្តសាងសង់បណ្តាញផ្លូវក្នុងតំបន់ក្រុង រហូតដល់ឆ្នាំ ២០៣០
- លើកកម្ពស់ស្ថាប័ន និងយុទ្ធនាការសម្រាប់ការពារសុវត្ថិភាពតាមផ្លូវថ្នល់
- ស្តារ និងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗ
- រៀបចំមធ្យោបាយដឹកជញ្ជូនសាធារណៈ និងពង្រឹងសមត្ថភាពស្ថាប័នសម្រាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព។

### ៥.៣.៤-ការពង្រឹងវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផល

- អភិវឌ្ឍធនធានមនុស្ស និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផល
- ចលនាភូមិមួយផលិតផលមួយ សម្រាប់ក្រុងកំពតមាន អំបិល ម្រេច ដូង ធុរេន និងទំស្លឹកចាក
- អភិវឌ្ឍភូមិផលិតកម្ម តាំងពិព័រណ៍ផលិតផល។

### ៥.៣.៥-ការគ្រប់គ្រងបរិស្ថាន

- ពង្រឹងសមត្ថភាពស្ថាប័ន
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- ប្រមូលកម្រៃរួមពីសេវាកម្មសាធារណៈ។

### ៥.៣.៦-ការគ្រប់គ្រងសំណល់រឹង

- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- ពង្រឹងប្រព័ន្ធប្រមូលសំណល់
- ពង្រឹងក្រុមការងារតាមដាន និងត្រួតពិនិត្យការប្រមូលសំរាម
- ពង្រឹងក្រុមកម្មករសម្អាតក្រុងកំពត
- រៀបចំសេចក្តីជូនដំណឹង និងដាក់ផ្ទាំងប៉ាណូកំណត់ពេលវេលាប្រមូលសំរាមតាមគោលដៅ
- រៀបចំសិក្ខាសាលាពិគ្រោះយោបល់តម្លៃសេវាប្រមូលសំរាមទីក្រុង តាមគោលការណ៍ណែនាំថ្មី
- រៀបចំការដេញថ្លៃរកម្ចាស់ផ្គត់ផ្គង់សេវាប្រមូលសំរាមថ្មីតាមខ្លឹមសារអនុក្រឹត្យលេខ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហាឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំកំណត់ដីទីលានទុកដាក់សំរាមដែលបានគ្រោងទុកថ្មី១៧.៤ ហិកតា ស្ថិតនៅឃុំព្រៃឃ្មុំ ស្រុកទឹកឈូ និងអភិវឌ្ឍតាមស្តង់ដារបច្ចេកទេស
- ដោះស្រាយទំនាស់ដីក្នុងទីលានទុកដាក់សំរាម
- សាងសង់រោងផលិតជីកំប៉ុស្តិនៅទីលានចាក់សំរាម
- ផ្សព្វផ្សាយអំពីបច្ចេកទេសផលិតជីកំប៉ុស្ត
- រៀបចំកម្មវិធីទស្សនៈកិច្ចសិក្សាទីតាំងផលិតជីកំប៉ុស្តិនៅក្រុងកំពត
- លើកទឹកចិត្តផលិតផលប្រើប្រាស់ជីធម្មជាតិ លក់ជីធម្មជាតិ និងផ្តល់បច្ចេកទេសផលិតជីកំប៉ុស្ត
- អប់រំផ្សព្វផ្សាយអំពីសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីណែនាំខេត្តស្តីពីការទុកដាក់ការពារសំណល់គ្រោះថ្នាក់
- ផលិតផ្ទាំងប៉ាណូអប់រំផ្សព្វផ្សាយ និងតាមវិទ្យុ
- ចុះធ្វើកិច្ចសន្យាគាំពារបរិស្ថានលើអាជីវកម្មពាក់ព័ន្ធនឹងសំណល់គ្រោះថ្នាក់ក្នុងក្រុង

- ចុះត្រួតពិនិត្យតាមដានលើអាជីវកម្មពាក់ព័ន្ធនឹងការបញ្ចេញសំណល់គ្រោះថ្នាក់
- រៀបចំសេចក្តីជូនដំណឹងអំពីការញែកសំរាមក្នុងក្រុងកំពត
- ផ្សព្វផ្សាយ និងណែនាំអំពីការញែកសំរាម សំណល់រឹង និងអនុវត្តជាក់ស្តែងដោយដាក់ធុងសំរាមក្នុងសាលាជាគំរូ
- រៀបចំកម្មវិធីទស្សនកិច្ចសិក្សាអំពីការកែច្នៃសំរាមនិងសំណល់ដល់សិស្ស
- ផលិតខ្លឹមសារសំខាន់ៗ ខ្លីៗ ងាយយល់លើកិច្ចគាំពារបរិស្ថាន និងការការពារធនធានធម្មជាតិ
- អនុវត្តន្តវិធានការច្បាប់ និងផាកពិន័យ
- សហការជាមួយជំនាញដើម្បីផលិតខ្លឹមសារអប់រំបរិស្ថាន។

### ៥.៣.៧- ប្រព័ន្ធលូបង្ហូរទឹកភ្លៀង និងការគ្រប់គ្រងសំណល់រាវ

- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន សំណង់អគារសេវាកម្មសាធារណៈ និងឯកជន ត្រូវរៀបចំអាងបង្គន់អនាម័យ និងអាងចម្រោះទឹកកខ្វក់ត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស។ កែលម្អអាងប្រព្រឹត្តកម្មទឹកកខ្វក់ដែលមានស្រាប់
- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង និងលូទឹកកខ្វក់ ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងអាងប្រព្រឹត្តកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវធ្វើចម្រោះទឹក ឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចូលទៅសមុទ្រ និងព្រែក
- រៀបចំសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ក្រៅក្រុង១កន្លែងក្នុងស្រុកទឹកឈូ និងនៅតាមសួនច្បារមាត់ព្រែកកំពត២ កន្លែងទៀត
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថានអនាម័យ។

### ៥.៣.៨- ធនធានទឹក និងការផ្គត់ផ្គង់ទឹកស្អាត

- ត្រួតពិនិត្យអ្នកប្រើប្រាស់បណ្តាញផ្គត់ផ្គង់ទឹកស្អាត
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹកព្រែកកំពត ព្រែកទឹកឈូ និងព្រែកស្ទឹងកែវ
- អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មីក្នុងក្រុងកំពត រហូតដល់ឆ្នាំ២០៣០
- អភិវឌ្ឍធនធានទឹកនៅព្រែកទឹកឈូ និងព្រែកស្ទឹងកែវ
- អភិវឌ្ឍរោងចក្រប្រព្រឹត្តកម្មទឹកស្អាត និងប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្រុងកំពតរហូតដល់ឆ្នាំ២០៣០។

### ៥.៣.៩-ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទូរគមនាគមន៍

- ពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនី
- ដំឡើង និងជួសជុលបណ្តាញអគ្គិសនីបំភ្លឺតាមដងវិថី
- ធ្វើផែនការប្រើប្រាស់ថាមពលអគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់
- ធ្វើផែនការផ្គត់ផ្គង់ថាមពលអគ្គិសនីដល់តំបន់ដែលពុំទាន់មានការប្រើប្រាស់
- កសាងសមត្ថភាពអគ្គិសនីកម្ពុជា
- ពិនិត្យឡើងវិញនូវអត្រាតម្លៃអគ្គិសនី
- ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ជា អំពីការផ្គត់ផ្គង់ថាមពលអគ្គិសនី ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន
- ស្រាវជ្រាវរកប្រភពថាមពលអគ្គិសនីប្រកបដោយចីរភាពសម្រាប់ក្រុងកំពត
- ពង្រីកបណ្តាញទូរគមនាគមន៍។

### ៥.៤-ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង

ផែនការសកម្មភាពចែកចេញជា ៣ ដំណាក់កាល គឺសម្រាប់ការអនុវត្តរយៈពេលខ្លី មធ្យម និងវែង ដូចខាងក្រោម÷

### ៥.៤.១-ការអនុវត្តរយៈពេលខ្លី

- គម្រោងអាទិភាពកែលម្អតំបន់កណ្តាលក្រុង
- ផែនការប្រើប្រាស់ដីសង្កាត់ទាំង៥ ក្នុងក្រុងកំពតដោយកំណត់បទប្បញ្ញត្តិប្រើប្រាស់ដី និងសំណង់។

### ៥.៤.២-ការអនុវត្តរយៈពេលមធ្យម

គម្រោងសំខាន់ៗតាមវិស័យក្រៅពីគម្រោងអាទិភាព។

### ៥.៤.៣-ការអនុវត្តរយៈពេលវែង

- ចំពោះសំណង់បណ្តោះអាសន្នតាមដងព្រែកកំពត តាមឆ្នេរសមុទ្រ តាមផ្លូវអយស្ម័យយាន និងការតាំងទីលំនៅដោយខុសច្បាប់ផ្សេងៗទៀតក្នុងក្រុង ត្រូវបន្តដោះស្រាយតាមសារាចរលេខ០៣ ស.រ ស្តីពីការដោះស្រាយសំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់ ក្នុងខេត្ត ក្រុង និងទីប្រជុំជន
- សិក្សាពីលទ្ធភាពនៃការធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាជនក្រីក្រគ្មានលំនៅឋាន និងប្រជាជនរស់នៅក្នុងសំណង់បណ្តោះអាសន្ន
- គម្រោងពង្រីកក្រុង ចាំបាច់ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របជាមុនដូចជា បណ្តាញផ្លូវ និងប្រព័ន្ធលូបង្ហូរទឹកកខ្វក់ ទឹកភ្លៀង អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ប្លង់បែងចែកតំបន់ប្រើប្រាស់ដីផ្សេងៗ

ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង មានជាអាទិ៍ តំបន់រដ្ឋបាល តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់សេវាកម្ម តំបន់អភិរក្ស លម្ហសាធារណៈ និងតំបន់បម្រុងទុកសម្រាប់ជាប្រយោជន៍សាធារណៈ និងការអភិវឌ្ឍនាពេលអនាគត ដើម្បីគ្រប់គ្រងការសាងសង់សំណង់គ្រប់ប្រភេទក្នុងតំបន់ទាំងនេះដោយអនុលោមតាមបទប្បញ្ញត្តិនគរូបនីយកម្ម និងគោលការណ៍អភិវឌ្ឍបៃតង សំដៅធ្វើឱ្យទីក្រុងក្លាយជាទីកន្លែងរស់នៅល្អ ប្រកបដោយសុខុមាលភាព គុណភាព វឌ្ឍនភាព និងចីរភាព។

## ៥.៥-គម្រោងអាទិភាព

- កែលម្អសោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធតំបន់កណ្តាលក្រុង
- កសាងសមត្ថភាពធ្វើផែនការក្រុង
- លើកកម្ពស់ការយល់ដឹងអំពីបរិស្ថាន
- អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទេសចរណ៍
- លើកកម្ពស់គុណភាពទេសចរណ៍ តាមរយៈភាពជាដៃគូរវាងរដ្ឋ ឯកជន
- អភិវឌ្ឍធនធានមនុស្ស និងបង្កើតមជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលកសិកម្ម
- ស្តារ និងជួសជុលបណ្តាញផ្លូវទៅកាន់តំបន់រមណីយដ្ឋានសំខាន់ៗ
- បំពាក់បំពង់បង្ហូរទឹកថ្មីជំនួសបំពង់ទឹកចាស់ៗ
- សិក្សាអំពីយុទ្ធសាស្ត្រសមាហរណកម្ម ការគ្រប់គ្រងធនធានទឹក ព្រៃកទឹកឈ្វ និងព្រៃកស្ទឹងកែវ
- អភិវឌ្ឍប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់កណ្តាលក្រុង
- រៀបចំ និងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងក្របខណ្ឌគតិយុត្តជាធរមាន
- បង្កើតភាពជាដៃគូរវាងរដ្ឋ និងឯកជន លើការគ្រប់គ្រងសំណល់រឹង និងរាវ
- អនុវត្តគោលគំនិត "ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ"
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនអំពីវិធានការគ្រប់គ្រងសំណល់រឹង និងរាវ
- ការពារ និងថែរក្សាឆ្នេរសមុទ្រធម្មជាតិ
- អភិរក្សធនធានធម្មជាតិ ដោយស្តារឡើងវិញនូវគម្របព្រៃឈើ ព្រៃកោងកាង និងធនធានសមុទ្រ
- ពង្រឹងសមត្ថភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម
- លើកទឹកចិត្តក្នុងការអភិវឌ្ឍតំបន់ឧស្សាហកម្មនៅក្រៅក្រុង
- ជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ និងសហគមន៍អេកូទេសចរណ៍
- សិក្សាផែនការអភិវឌ្ឍន៍វិស័យដឹកជញ្ជូន និងឡជីស្ទីកគ្រប់ជ្រុងជ្រោយ រវាងខេត្តកំពត និងរាជធានីភ្នំពេញ
- រៀបចំប្រព័ន្ធត្រួតពិនិត្យ ឱ្យមានលក្ខណៈអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព

- រៀបចំនិងអង្កេតទីផ្សារ ផ្សព្វផ្សាយ អភិវឌ្ឍចំណតរថយន្ត ជំរុញការដឹកជញ្ជូនតាមផ្លូវអេយស្ម័យយាន និងអភិវឌ្ឍន៍កំពង់ផែ ឱ្យឆ្លើយតបនឹងតម្រូវការ
- កែលម្អផ្លូវមេ និងផ្លូវចែកចាយក្នុងតំបន់ក្រុង
- កែលម្អផ្លូវចូលកាន់កំពង់ផែទេសចរណ៍ ទៅរមណីយដ្ឋានទឹកឈូ និងរមណីដ្ឋាយនភ្នំដូង
- រៀបចំ និងកែលម្អផ្លូវតភ្ជាប់ផ្លូវមាត់ព្រែកត្រើយខាងលិច ពីចំណុចស្ពានត្រើយកោះ ដល់ស្ពានចាស់ និងកែលម្អស្ពានដែលមាន ស្រាប់ចំនួន៤ ឆ្លងកាត់ព្រែកកំពត
- រៀបចំកន្លែងស្តុកទឹក
- បំពាក់ប្រព័ន្ធចែកចាយទឹកពីបំពង់មេ និងបំពាក់ឧបករណ៍មួយចំនួនសម្រាប់នាំទឹកដែលច្រោះរួច
- កែលម្អ និងរៀបចំឡើងវិញនូវប្រព័ន្ធចែកចាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពបត់បែន និងកាត់បន្ថយសម្ពាធក្នុងផ្នែកផ្សេងៗនៃប្រព័ន្ធ
- ពង្រីកមធ្យោបាយនៃការធ្វើប្រព្រឹត្តិកម្មទឹកកខ្វក់
- ធ្វើឱ្យសេវាតភ្ជាប់កាន់តែមានភាពចាំបាច់
- ផ្តោតសំខាន់លើការធ្វើប្រព័ន្ធលូ និងអាងប្រព្រឹត្តិកម្មទឹកកខ្វក់ចេញពីតំបន់ទាំងបី មានតំបន់កណ្តាលក្រុងផ្នែកខាងកើតព្រែក មានសង្កាត់កំពង់កណ្តាល សង្កាត់កំពង់បាយ និងសង្កាត់អណ្តូងខ្មែរ ផ្នែកខាងលិច និងខាងត្បូងព្រែក មានសង្កាត់អណ្តូងខ្មែរ និងសង្កាត់ត្រើយកោះ។

## ៦-ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកំពត មានជាអាទិ៍÷

- ថវិកាជាតិ
- ថវិកាអភិវឌ្ឍន៍និងវិនិយោគដោយវិស័យឯកជន
- ថវិកាវិនិយោគរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍និងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧-ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

### ៧.១-យន្តការ

យន្តការថ្នាក់ជាតិ ដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០ មាន÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្ត មាន÷ រដ្ឋបាលខេត្តកំពត គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពត គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងកំពត មន្ទីរ អង្គភាពជុំវិញខេត្ត និងអាជ្ញាធរក្រុង សង្កាត់។

### ៧.២-ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើច្បាប់ គោលនយោបាយ និងក្របខ័ណ្ឌគតិយុត្ត មានជាអាទិ៍÷ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ច្បាប់ស្តីពីទេសចរណ៍ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីអស្សាមិករណ៍ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន គោលនយោបាយដីធ្លី (សៀវភៅសដីធ្លី) គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សេចក្តីសម្រេចស្តីពីនីតិវិធីលម្អិតនៃការរៀបចំប្លង់គោល និងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៧.៣-ភារកិច្ច នីតិវិធី និងគោលការណ៍

រដ្ឋបាលក្រុងកំពត ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងកំពត ជាសេនាធិការ មានភារកិច្ច÷

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកំពត ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍន៍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើ ត្រូវកំណត់នូវគោលបំណង គោលដៅសកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗ សម្រាប់ការ

ត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ ឆ្នាំ កម្មវិធីវិនិយោគ៣ ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្មថ្នាក់ក្រុង សង្កាត់

- ត្រូវធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដីនេះ ក្នុងរយៈពេល៥ ឆ្នាំម្តង ស្របតាមគោលការណ៍ និងនីតិវិធីដែលបានកំណត់ ឬតាមពេលវេលា និងតម្រូវការចាំបាច់ជាក់ស្តែងសំដៅបម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តប្លង់គោលប្រើប្រាស់ដីនេះជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពត រដ្ឋបាលខេត្តកំពត ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីធ្វើការបូកសរុបនិងធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាល។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដី និងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដែលជាកត្តាគូសបញ្ជាក់អំពីប្រសិទ្ធភាពនៃប្លង់គោលប្រើប្រាស់ដីក្រុងកំពតក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព។

## ៨-សេចក្ដីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយ ឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ប្លង់គោលប្រើប្រាស់ដីក្រុងកំពត ត្រូវបានរៀបចំឡើង និងសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោលដ៏មានសារៈសំខាន់ សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យ ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣០ គឺ "**ក្រុងកំពតជាក្រុង គុជបៃតង ឆ្នេរសមុទ្រ ធម្មជាតិ វប្បធម៌ និងពាណិជ្ជកម្ម តាមរយៈការអភិវឌ្ឍជាទីក្រុង ១). រមណីយដ្ឋានគុជទេសចរណ៍ឆ្នេរសមុទ្រ ទេសភាពធម្មជាតិ និងវប្បធម៌ ដែលស្អាតបំផុតលើសកលលោក ២). មជ្ឈមណ្ឌលកែច្នៃផលិតផលកសិកម្ម ឧស្សាហកម្ម ៣).ទីផ្សារអន្តរជាតិសម្រាប់ផលិតផលកសិកម្ម និងចែកចាយទំនិញ ៤). គ្រប់គ្រោងអភិបាលកិច្ចល្អ**" និងដើម្បីរួមចំណែកអភិវឌ្ឍន៍និងប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនផ្នែកធុរកិច្ច និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្តតាមដាន និងវាយតម្លៃចំពោះប្លង់គោលប្រើប្រាស់ដីក្រុងកំពត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មគ្រប់លំដាប់ថ្នាក់ និងអាជ្ញាធរមានសមត្ថកិច្ចត្រូវជំរុញការផ្សព្វផ្សាយ និងអនុវត្តន៍តាមប្លង់គោលប្រើប្រាស់ដីក្រុងកំពតឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់ដើម្បីធានាការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ហើយត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

## ៩- អនុសាសន៍

ដើម្បីឱ្យប្លង់គោលប្រើប្រាស់ដីក្រុងកំពត អនុវត្តមានប្រសិទ្ធភាព រដ្ឋបាលក្រុង រដ្ឋបាលខេត្ត ត្រូវយកចិត្តទុកដាក់÷

**ទី១.** អនុវត្តបទប្បញ្ញត្តិ ប្រើប្រាស់ដីតាមតំបន់នីមួយៗ និងត្រូវបន្តរៀបចំផែនការប្រើប្រាស់ដី ព្រមទាំងប្លង់លម្អិតនគរូបនីយកម្ម ចុះបញ្ជីដីធ្លីឱ្យបានច្បាស់លាស់ និងរៀបចំបទប្បញ្ញត្តិនានា ក្នុង ការគ្រប់គ្រងប្រើប្រាស់ដី និងសំណង់ឱ្យមានប្រសិទ្ធភាព

**ទី២.** រៀបចំផែនការសកម្មភាព និងគម្រោងវិនិយោគតាមលំដាប់អាទិភាពដើម្បីធ្វើការផ្សព្វផ្សាយកៀរគររកដៃគូអភិវឌ្ឍន៍ និងអ្នកវិនិយោគទុនស្របតាមច្បាប់វិនិយោគ និងបទដ្ឋានគតិយុត្ត ជាធរមាន

**ទី៣.** លើកកម្ពស់សមត្ថភាពមន្ត្រី និងបណ្តុះបណ្តាលធនធានមនុស្សថ្នាក់ ខេត្ត និងថ្នាក់ក្រុង ដើម្បីធានាការគ្រប់គ្រង និងអភិបាលកិច្ចល្អ

**ទី៤.** តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកំពតប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ព្រមទាំងរៀបចំធ្វើបច្ចុប្បន្នភាពប្លង់គោលប្រើប្រាស់ដី ដើម្បីស្នើសុំការអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ស្របតាមបទដ្ឋានគតិយុត្តជាធរមាន

**ទី៥.** រៀបចំកញ្ចប់ថវិកាថ្នាក់ខេត្ត និងថ្នាក់ក្រុង សម្រាប់អនុវត្តន៍គម្រោងផែនការជួសជុល ថែទាំ និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាសាធារណជន និងលម្ហសាធារណៈ

**ទី៦.** ស្នើសុំសហការ និងគាំទ្រពីគ្រប់ក្រសួងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីធានាការអនុវត្តប្លង់គោលប្រើប្រាស់ដីក្រុងកំពតឱ្យមានប្រសិទ្ធភាព ចីរភាព តុល្យភាព និងសមាហរណកម្មល្អប្រសើរ៕

## សន្ទានុក្រម

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំង តំបន់ទទួលឥទ្ធិពលក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភ័ណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ ថ្នាក់ខេត្ត** ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្តានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យ និងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្ត និងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាន និងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្តាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍ និងអភិរក្សទីក្រុងទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ជានៃការប្រើប្រាស់ដីជាក់ស្តែង ការសាងសង់ ការអភិវឌ្ឍដី និងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្តាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់រំលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍន៍ទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបវន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភ័ណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្ស និងការសាងសង់តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាល និងសេវាសាធារណៈ តំបន់លម្ហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌ និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបនកសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់ សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**ប៉ូលអភិវឌ្ឍន៍** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

**តំបន់លម្ហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលម្ហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**បណ្តាណបៃតង** សំដៅដល់សួនសាធារណៈ និងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមចិញ្ចើមផ្លូវភ្ជាប់ទៅសួនទីក្រុង។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ឆ្នេរសមុទ្រ** សំដៅដល់ចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្តងម្កាល។ ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្ម ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០ (សាមសិប) ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ) ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្តែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបានទំហំឆ្នេរសមុទ្រត្រូវកែច្នៃ ឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

**ដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រ ជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែង ឬទំហំដីចំណីឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច ៥០ (ហាសិប) ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្តោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់ មកទល់នឹងផ្លូវសាធារណៈនេះ។

**តំបន់រណប** សំដៅដល់តំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្តោយឆ្នេរសមុទ្រ និងផ្លូវស្របបន្ទាប់មួយទៀតដែលស្ថិតក្នុងទិសខាងដីគោក។

**ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

**ផ្លូវសាធារណៈតាមបណ្តោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃ សមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។

**ដែសមុទ្រ** សំដៅដល់ផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដែសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដែសមុទ្រត្រូវកំណត់ចម្ងាយ៣០(សាមសិប) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

**ផ្លូវទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ** សំដៅដល់ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ២០(ម្ភៃ) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

**កោះ** សំដៅដល់ផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

**ដែនទឹកសមុទ្រ** សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះគ្រប់ប្រភេទ។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់ បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្ទៃកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរង ទឹកភ្លៀងនៅផ្ទៃកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀង នៅផ្ទៃកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះ ដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

**បឹងបួ** សំដៅដល់ល្ហលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

**ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រកសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរិលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមនីយដ្ឋាន ឬមជ្ឈមណ្ឌលកម្សាន្ត។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការ ផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាណលូមេរង បណ្តាណលូខ្នែង និងបណ្តាណលូខ្នែងរង។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

# ឯកសារខ្ជាប់សម្ព័ន្ធ

- របាយការណ៍បច្ចេកទេសលម្អិតប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ ២០៣០
- ផែនទីបែងចែកតំបន់ប្រើប្រាស់ដីក្រុងកំពត
- ផែនទីហេដ្ឋារចនាសម្ព័ន្ធក្រុងកំពត
- ផែនទីបណ្ដាញផ្លូវថ្នល់ក្រុងកំពត
- ផែនទីព្រំប្រទល់រដ្ឋបាលក្រុងកំពត
- ផែនទីរូបថតពីលើអាកាសក្រុងកំពត៕

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តកំពត
គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកំពត

# ផែនទី បណ្ដាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធ ក្រុងកំពត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ







ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្តោយទី១០២ អង្សា ដល់ ១០៨អង្សា និង រយៈទទឹងទី១២អង្សា ដល់ ១៥អង្សា ។




ប្រទេសកម្ពុជាមានផ្ទៃដីសរុប ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា មានបណ្តោយ ៥៦០ គីឡូម៉ែត្រ និង មានទទឹង ៤៤០គីឡូម៉ែត្រ ។ ប្រទេសកម្ពុជាមានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាមប្រវែង ២១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០គីឡូម៉ែត្រ ។

## ផែនទីក្រុងកំពត

ក្រុងកំពត ស្ថិតនៅជាប់នឹងតំបន់ឆ្នេរសមុទ្រ នៅប៉ែកនិរតីនៃប្រទេស មានចំងាយ១៤៨គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានផ្ទៃដីគោតសរុប ៥៤គីឡូម៉ែត្រក្រឡា ចែកចេញជា ៥សង្កាត់ គឺសង្កាត់កំពង់បាយ ក្រាំងអំពិល កំពង់កណ្តាល អណ្តូងខ្មែរ និងសង្កាត់ត្រើយកោះ ។ ឆ្នាំ២០១៧ក្រុងកំពតមានប្រជាជនចំនួន ៣៧ ៩៩៥នាក់ ឆ្នាំ ២០១៨ ចំនួន ៣៩ ០៨១នាក់ និងតាមការធ្វើចំណោលប្រជាសាស្ត្រ ដោយគណនាតាមអត្រាកំណើនប្រចាំឆ្នាំ ក្រុងកំពតឆ្នាំ២០៣០ នឹងមានប្រជាជនកើនដល់ចំនួន ៤៥ ១៨៤ នាក់ ។




## ការពិពណ៌នា

-ផែនទីនេះត្រូវបានផលិតឡើងនៅខែមករា ឆ្នាំ២០១៨ ដែលបង្ហាញពីការបែងចែកតំបន់ប្រើប្រាស់ដីក្នុងក្រុងកំពតនាពេលអនាគត មានដូចជា តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់កសិកម្ម តំបន់រដ្ឋបាល តំបន់ទេសចរណ៍ និងតំបន់លំហសាធារណៈ ។ល។

-ផែនទីនេះត្រូវបានរៀបចំឡើងដោយក្រុមការងារមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត សហការជាមួយក្រុមការងារគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកំពត និងក្រុមការងារគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពត ។

-ការរៀបចំផែនទីនេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើរូបថតពីលើអាកាស ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រូបថត Google Earth និងទិន្នន័យរបស់អង្គការ JICAឆ្នាំ២005 ដោយរួមជាមួយការចុះអង្កេតដោយផ្ទាល់ នៅតំបន់សិក្សា ដោយប្រើប្រាស់ឧបករណ៍GPS ដើម្បីស្រង់នូវនិយាមកានៃបណ្តាញផ្លូវដែលមានស្រាប់ ទីតាំងរដ្ឋបាលសាធារណៈ និងតំបន់ប្រើប្រាស់ដី ។

-តំបន់ប្រើប្រាស់ដីបានធ្វើការបែងចែកដោយផ្អែកទៅលើប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន រួមជាមួយលក្ខណៈចាំបាច់ផ្សេងៗទៀតនៃតំបន់ ។

## មាត្រដ្ឋានផែនទី

មាត្រដ្ឋាន : 1:22,000

0.5 0.25 0 0.5 1 1.5 2 គ.ម

សន្និកម្ពស់:

## ប្រព័ន្ធនិយមការ

ប្រើចំពីរាងពងក្រពើ..............អេល្លីបហ្វូអ៊ីត..............ដប់ប៊ិលយូ ជី អេស៍១៩៨៤
បណ្តាញក្រលាចតុរង្គ.........យូ ធី អឹម..........១គីឡូម៉ែត្រ............មួយជ្រុង..............ផ្អែកផ្ទៃរង្វង់មណ្ឌល លេខ ៤៨
បញ្ចុះបែងភាគប្រើចំពីជា..............ត្រង់ស្វែតមាកូទ័រ
កំណត់កំពស់..............យកតាមផ្ទៃរាបនៃទឹកសមុទ្រនៅហាទៀង
កំណត់បណ្តាញនៃប្រើចំពីរិភាគ..............យកតាមបណ្តាញប្រើចំពីរិភាគ ដប់ប៊ិលយូ ជី អេស៍១៩៨៤

**Coordination System**

Spheroid..............WGS_1984
Grid..............1,000 Metre..............UTM: Zone 48
Projection..............Transverse Mercator
Vertical Datum..............Mean Sea Level at Ha Tieng
Horzontal Datum..............WGS Datum 1984

## ការពិពណ៌នា

-ការកំណត់ព្រំប្រទល់ទីក្រុងកំពតនេះ យកតាមទិន្នន័យ JICA ។
-ផែនទីរដ្ឋបាលក្រុងកំពតរួមមានព្រំប្រទល់ក្រុង សង្កាត់ និងចំណុចទីតាំង សាលាខេត្ត សាលាក្រុង សាលាសង្កាត់ និង ភូមិ និងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក ស្ពាន ។
-ផែនទីនេះជាពង្រាងរបស់គណកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ ក្រុង និងខេត្តកំពត និងក្រុមការងាររៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីខេត្តកំពត ។
-ផែនទីនេះត្រូវបាបបង្កើតឡើងនៅថ្ងៃទី០១ខែមករាឆ្នាំ២០១៨ ។

## ប្រភពទិន្នន័យ

-រូបថតលើអាកាសនៅឆ្នាំ១៩៩២-៩៣និងផែនទីឋានលេខាមាត្រដ្ឋាន(១:១00000)ទទួលបានពីនាយកដ្ឋានភូមិសាស្ត្រ ។ ទិន្នន័យនេះប្រើសំរាប់កសាង និងផ្ទៀងផ្ទាត់ទិន្នន័យដទៃទៀត ។
-ទិន្នន័យផ្សេងៗទៀត: បង្កើតឡើងដោយពឹងផ្អែកលើរូបថតពីលើអាកាស និងការចុះស្រង់ទិន្នន័យដោយផ្ទាល់និងទីកន្លែង ដោយប្រើ ជី ភី អេស ដែលមានកំរិតលំអៀង៣ម៉ែត្រ ។
-ផែនទីក្រុងកំពតធ្វើការ Digitize ដោយផ្អែកលើរូបថតពីលើអាកាស ឆ្នាំ ១៩៩២-៩៣ និងចុះអង្កេតព្រមទាំងប្រៀបធៀបនឹងផែនទីតូចម៉ាប់ដែលមានស្រាប់ ។

## ព្រំប្រទល់: ប្រទេស ស្រុក និង ឃុំ

-ទិន្នន័យនេះបានមកពីទិន្នន័យរបស់ អង្គការ JICA របស់ជប៉ុន(ផលិតឡើងឆ្នាំ២00៥) ដែលផ្តល់អោយដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រើប្រាស់ជាផ្លូវការ ។
-ទិន្នន័យនេះ ក្រុមការងារក៏បានពិភាក្សា និង ផ្ទៀងផ្ទាត់ឡើងវិញជាមួយនិងអជ្ញាធរមូលដ្ឋានផងដែរ ដើម្បីបញ្ជាក់បន្ថែម និងភាពជាក់លាក់ព្រំប្រទល់រដ្ឋបាលរបស់តំបន់ទីប្រជុំជន ។

## ផ្លូវទឹក ផ្លូវថ្នល់ សំណង់ហេដ្ឋានរចនាសម្ព័ន្ធ និងអគារសាធារណៈ

-ទិន្នន័យបង្កើតឡើងដោយរូបថតពីលើអាកាសក្នុងអំឡុងឆ្នាំ១៩៩២-៩៣ និង ការចុះស្រង់ទិន្នន័យដោយផ្ទាល់និងទីកន្លែង ដោយប្រើ ជីភីអេស ដែលមានកំរិតលំអៀង ៣ ម ។

គាំទ្របច្ចេកទេសដោយ : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

សិក្សាដោយ : -គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងកំពត ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការដឹកនាំដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត
-គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងកំពត ដែលមានក្រុមការងារមួយជាសេនាធិការដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងកំពត ។

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពត
គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងកំពត

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទី ព្រំប្រទល់រដ្ឋបាល ក្រុងកំពត
## ( ដង់ស៊ីតេប្រជាជន ក្រុងកំពត ឆ្នាំ២០១៨ និងឆ្នាំ២០៣០ )




### ផែនទីតំបន់ឥណ្ឌូចិន




ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដែលមានរយៈបណ្ដោយទី១០២ អង្សា ដល់ ១០៨អង្សា និង រយៈទទឹងទី១២អង្សា ដល់ ១៥អង្សា ។




ប្រទេសកម្ពុជាមានផ្ទៃដីសរុប ១៨១ ០៣៥ គីឡូម៉ែត្រក្រឡា មានបណ្ដោយ ៥៦០ គីឡូម៉ែត្រ និង មានទទឹង ៤៤០គីឡូម៉ែត្រ ។ ប្រទេសកម្ពុជាមានព្រំប្រទល់ដីគោកជាប់នឹងប្រទេសថៃ ប្រទេសឡាវ និងប្រទេសវៀតណាមប្រវែង ២១៦០ គីឡូម៉ែត្រ និងមានឆ្នេរសមុទ្រប្រវែង ៤៤០គីឡូម៉ែត្រ ។

### ផែនទីក្រុងកំពត

ក្រុងកំពត ស្ថិតនៅជាប់នឹងតំបន់ឆ្នេរសមុទ្រ នៅប៉ែកនិរតីនៃប្រទេស មានចំងាយ១៤៨គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានផ្ទៃដីគោកសរុប ៥៤គីឡូម៉ែត្រក្រឡា ចែកចេញជា ៥សង្កាត់ គឺសង្កាត់កំពង់បាយ ក្រាំងអំពិល កំពង់កណ្ដាល អណ្ដូងខ្មែរ និងសង្កាត់ត្រើយកោះ ។ ឆ្នាំ២០១៧ក្រុងកំពតមានប្រជាជនចំនួន ៣៧ ៥៥៥នាក់ ឆ្នាំ ២០១៨ ចំនួន ៣៩ ០៨១នាក់ និងតាមការធ្វើចំណោលប្រជាសាស្ត្រដោយគណនាតាមអត្រាកំណើនប្រចាំឆ្នាំ ក្រុងកំពតឆ្នាំ២០៣០ នឹងមានប្រជាជនកើនដល់ចំនួន ៤៥ ១៨៤ នាក់ ។




### សញ្ញាសំគាល់

- ទីតាំងសាលាខេត្ត
- ទីតាំងសាលាស្រុក ក្រុង
- ទីតាំងសាលាសង្កាត់ ឃុំ
- ទីតាំងភូមិ
- ព្រំប្រទល់ប្រទេស
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់ក្រុង ស្រុក
- ព្រំប្រទល់ឃុំ,សង្កាត់

- ប្រជាជនក្រុងកំពតឆ្នាំ២០១៨ មានចំនួន ៣៩០៨១ នាក់ មានដង់ស៊ីតេប្រជាជន ស្មើនឹង ៧២៣.៧២ នាក់/គម²
- ប្រជាជនក្រុងកំពតឆ្នាំ២០៣០: មានចំនួន ៤៥១៨៤ នាក់ មានដង់ស៊ីតេប្រជាជន ស្មើនឹង ៩១០.៨១ នាក់ /គម²

### មាត្រដ្ឋានផែនទី

មាត្រដ្ឋាន : 1:22,000

0.5 0.25 0 0.5 1 1.5 2 គ.ម

**សន្លឹកម្ចង់:**

### ប្រព័ន្ធនិយមការ

ប្រព័ន្ធពិភពលោកក្រលើ......................អេល្លីបហ្ស៊ុអ៊ីត......................ដប់បិលយូ ជី អេស៍១៩៨៤
បណ្ដាញក្រឡាចតុរង្គ..........យូ ធី អឹម..........១គីឡូម៉ែត្រ..........មួយជ្រុង..........ផ្ទៃកផ្ទៃវណ្ឌមណ្ឌល លេខ ៤៨
បញ្ចុះបែងភាគប្រព័ន្ធពីជា......................ត្រង់ស្វែតមាក្កទ័រ
កំណត់កំពស់......................យកតាមផ្ទៃរាបនៃទឹកសមុទ្រនៅហាទៀង
កំណត់បណ្ដាញនៃប្រព័ន្ធពីវិភាគ......................យកតាមបណ្ដាញប្រព័ន្ធពីវិភាគ ដប់បិលយូ ជី អេស៍១៩៨៤

**Coordination System**

Spheroid......................WGS_1984
Grid......................1,000 Metre......................UTM: Zone 48
Projection......................Transverse Mercator
Vertical Datum......................Mean Sea Level at Ha Tieng
Horzontal Datum......................WGS Datum 1984

### ការពិពណ៌នា

-ការកំណត់ព្រំប្រទល់ទីក្រុងកំពតនេះ យកតាមទិន្នន័យ JICA ។
-ផែនទីរដ្ឋបាលក្រុងកំពតរួមមានព្រំប្រទល់ក្រុង សង្កាត់ និងចំណុចទីតាំង សាលាខេត្ត សាលាក្រុង សាលាសង្កាត់ និង ភូមិ និងហេដ្ឋារចនាសម្ព័ន្ធ ផ្លូវថ្នល់ ផ្លូវទឹក ផ្លូវដែក ស្ពាន ។
-ផែនទីនេះជាពង្រាងរបស់គណកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ ក្រុង និងខេត្តកំពត និងក្រុមការងាររៀបចំប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដីខេត្តកំពត ។
-ផែនទីនេះត្រូវបានបង្កើតឡើងនៅថ្ងៃទី០១ខែមករាឆ្នាំ២០១៨ ។

### ប្រភពទិន្នន័យ

-រូបថតលើអាកាសនៅឆ្នាំ១៩៩២-៩៣និងផែនទីឋានលេខាមាត្រដ្ឋាន(១:១០០០០០)ទទួលបានពីនាយកដ្ឋានភូមិសាស្ត្រ ។ ទិន្នន័យនេះប្រើសំរាប់កសាង និងផ្ទៀងផ្ទាត់ទិន្នន័យដទៃទៀត ។
-ទិន្នន័យផ្សេង១ទៀត: បង្កើតឡើងដោយពឹងផ្អែកលើរូបថតពីលើអាកាស និងការចុះស្រង់ទិន្នន័យដោយផ្ទាល់និងទីកន្លែង ដោយប្រើ ជី ភី អេស ដែលមានកំរិតលំអៀង៣ម៉ែត្រ ។
-ផែនទីក្រុងកំពតធ្វើការ Digitize ដោយផ្អែកលើរូបថតពីលើអាកាស ឆ្នាំ ១៩៩២-៩៣ និងចុះអង្កេតព្រមទាំងប្រៀបធៀបនឹងផែនទីតូចម៉ាប់ដែលមានស្រាប់ ។

### ព្រំប្រទល់: ប្រទេស ស្រុក និង ឃុំ

-ទិន្នន័យនេះបានមកពីទិន្នន័យរបស់ អង្គការ JICA របស់ជប៉ុន(ផលិតឡើងឆ្នាំ២០០៥) ដែលផ្តល់អោយដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីប្រើប្រាស់ជាផ្លូវការ ។
-ទិន្នន័យនេះ ក្រុមការងារក៏បានពិភាក្សា និង ផ្ទៀងផ្ទាត់ឡើងវិញជាមួយនិងអជ្ញាធរមូលដ្ឋានផងដែរ ដើម្បីបញ្ជាក់បន្ថែម និងភាពជាក់លាក់ព្រំប្រទល់រដ្ឋបាលរបស់តំបន់ទីប្រជុំជន ។

### ផ្លូវទឹក ផ្លូវថ្នល់ សំណង់ហេដ្ឋារចនាសម្ព័ន្ធ និងអគារសាធារណៈ:

-ទិន្នន័យបង្កើតឡើងដោយរូបថតពីលើអាកាសក្នុងអំឡុងឆ្នាំ១៩៩២-៩៣ និង ការចុះស្រង់ទិន្នន័យដោយផ្ទាល់និងទីកន្លែង ដោយប្រើ ជីភីអេស ដែលមានកំរិតលំអៀង ៣ ម ។

គាំទ្របច្ចេកទេសដោយ : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ
សិក្សាដោយ : -គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងកំពត ដែលមានលេខាធិការដ្ឋានមួយជាសេនាធិការដឹកនាំដោយ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពត
-គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មក្រុងកំពត ដែលមានក្រុមការងារមួយជាសេនាធិការដឹកនាំដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងកំពត ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនទីប្លង់គោលប្រើប្រាស់ដីក្រុងកំពត ចក្ខុវិស័យឆ្នាំ២០៣០

ឧបសម្ព័ន្ធនៃសេចក្តីសម្រេចលេខ:............ ចុះថ្ងៃ............ខែ............ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ត្រូវនឹងថ្ងៃទី ......ខែ......ឆ្នាំ ២០១៨




## ការពិពណ៌នា

-ផែនទីនេះត្រូវបានផលិតឡើងនៅខែមករា ឆ្នាំ២០១៨ ដែលបង្ហាញពីការបែងចែកតំបន់ប្រើប្រាស់ដីក្នុងក្រុងកំពតនាពេលអនាគត មានដូចជា តំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់កសិកម្ម តំបន់រដ្ឋបាល តំបន់ទេសចរណ៍ និងតំបន់លំហសាធារណៈ ។ល។

-ផែនទីនេះត្រូវបានរៀបចំឡើងដោយក្រុមការងារមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត សហការជាមួយក្រុមការងារគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មក្រុងកំពត និងក្រុមការងារគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្តកំពត ។

-ការរៀបចំផែនទីនេះ ត្រូវបានធ្វើឡើងដោយផ្អែកទៅលើរូបថតពីលើអាកាស ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រូបថត Google Earth និងទិន្នន័យរបស់អង្គការ JICAឆ្នាំ២០០៥ ដោយរួមជាមួយការចុះអង្កេតដោយផ្ទាល់ នៅតំបន់សិក្សា ដោយប្រើប្រាស់ឧបករណ៍GPS ដើម្បីស្រង់នូវនិយាមកានៃបណ្តាញផ្លូវដែលមានស្រាប់ ទីតាំងរដ្ឋបាលសាធារណៈ និងតំបន់ប្រើប្រាស់ដី ។

-តំបន់ប្រើប្រាស់ដីបានធ្វើការបែងចែកដោយផ្អែកទៅលើប្រភេទនៃការប្រើប្រាស់ដីបច្ចុប្បន្ន រួមជាមួយលក្ខណៈចាំបាច់ផ្សេងៗទៀតនៃតំបន់ ។

## មាត្រដ្ឋានផែនទី

មាត្រដ្ឋាន : 1:22,000

0.5 0.25 0 0.5 1 1.5 2 គ.ម

សន្លឹកទី: ០១